R. 6 7-10-52
Tossanavaddey
INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

## ព្រះរាជាណាចក្រកម្ពុជា

## មន្ទីរស្ដីការក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

# គ្រូបង្រៀន

ឆ្នាំទី៤ Sept-octobre លេខ ១-២

ខែកញ្ញានិងតុលា ព.ស.២៤៩៥

ឆ្នាំសិក្សា ១៩៥២-១៩៥៣

52 -
(1-2)

# ព្រះរាជអាណាចក្រកម្ពុជា

## មន្ទីរស្តីការក្រសួងសិក្សាធិការ

# ទស្សនាវដ្តី សម្រាប់គ្រូបង្រៀន

បញ្ជីរឿង ទំព័រ


សេចក្តីណែនាំ .. ... ... ... .. ... ... .. ... .. ... ៣

ឧត្តមដ្ឋាន – មធ្យមដ្ឋានទី ២ ភាសា ... ... .. ... .. ... ៩

មធ្យមដ្ឋានទី ១ ភាសា ... .. ... .. .. ... ១៧

អាទិកដ្ឋាន ភាសា .. ... ... .. ... .. ១៩

បទិវច្ចណដ្ឋាន ភាសា ... .. .. ... .. ... ២៥

កុមារដ្ឋាន ភាសា .. .. ... ... ... .. ២៩

តែងសេចក្តីសម្រាប់ប្រឋមភូមិបំពេញវិជ្ជា ... .. ... ... ... ៣៦

តែងសេចក្តីសម្រាប់ប្រឋមភូមិជាន់ដំបូង .. .. .. ... ... .. ៤១

អាទិកដ្ឋាន – នព្វន្ត – រង្វាស់រង្វាល់ ... ... ... ... ... ៤៦

បរិវច្ចណដ្ឋាន – នព្វន្ត – រង្វាស់រង្វាល់ .. .. .. ... .. ... ៥៥

គមារដ្ឋាន – នព្វន្ត – រង្វាស់រង្វាល់ ... ... ... ... .. ... ៦០

អាទិកដ្ឋាន – វត្ថុស្វាធ្យាយន៍ – វិធីបង្ការរោគ ... ... .. ... ៦៧

បរិវចណដ្ឋាន – វត្ថុស្វាធ្យាយន៍ – វិធីបង្ការរោគ .. .. ... .. ៧៤

កុមារដ្ឋាន – វត្ថុស្វាធ្យាយន៍ – វិធីបង្ការរោគ .. .. .. .. .. ៧៩

លោកនិតិ សម្រាប់គ្រប់ថ្នាក់ .. .. .. .. ... ... .. ... .. ៨៦

មេសូត្រតែមាត់ ... ... ... ... ... ... ... ... ... ... ៩៣

# សេចក្ដីណែនាំ

ក្នុងទស្សនាវដ្ដីជាដំបូងនេះ យើងអធិប្បាយណែនាំពីការរួបរួមតាំងអស់ប្រយោជន៍លោកជាគ្រូចាត់ចែងតែងរបៀបបង្រៀនៗដល់ទស្សនាវដ្ដីក្រោយ ៗ ទៀត នឹងអធិប្បាយចំពោះពីរបៀបបង្រៀនមេរៀនផ្សេង ៗ ដើម្បីលោកជាគ្រូបង្រៀន នឹងបានជ្រាបអំពីកិច្ចការដែលត្រូវបង្រៀននោះ គឺការអ្វី ៗ ដែលលោកពុំបានជ្រាបនឹងបានជ្រាបឡើង ការអ្វី ៗ ដែលលោកបានសិក្សានៅសាលាបំពេញវិជ្ជារួចហើយ ៗ លោកភ្លេចទៅវិញ នឹងបានជ្រាបឡើងវិញ ។

ធ្វើដូច្នេះយើងសង្ឃឹមថាជាការនាំឲ្យស្រួលហើយឲ្យងាយនឹងបង្រៀនផង លោកជាគ្រូបង្រៀនពុំសូវពិបាកហើយនឹងបានប្រយោជន៍យ៉ាងសំខាន់ ៗ ប៉ុន្ដែដែលនឹងឲ្យបានសំរេចប្រយោជន៍នេះ សូមលោកគ្រូមើលសេចក្ដីអធិប្បាយដោយពិនិត្យពិចៃ សូមរៀនឲ្យចាំហើយយកទៅធ្វើតាមផង ៗ

## ការដែលលោកជាគ្រូបង្រៀនត្រូវធ្វើវេលាដែលចូលរៀនវិញ

តាំងពីថ្ងៃរៀនដំបូងលោកគ្រូគ្រប់គ្នាត្រូវធ្វើដូចមានសេចក្ដីរាយខាងក្រោមនេះ ។

១– កត់ឈ្មោះកូនសិស្សនៅបញ្ជីហៅឈ្មោះរាល់ថ្ងៃ ។

២– កត់ឈ្មោះកូនសិស្សនឹងសេចក្ដីពិតមានគ្រប់ប្រការនៅបញ្ជីធំ បើមានបញ្ជីនោះនៅសាលា ។

៣– រៀបកូនសិស្សដាក់តាមថ្នាក់ឬតាមចំណែក ។

៤– ប្ដឹងចៅហ្វាយស្រុកឬមេឃុំពីកូនសិស្សណាដែលមិនមករៀន

៥– សូមបើករបស់សម្រាប់បង្រៀន បើគ្មានរបស់នោះ ។

៦– ពិនិត្យមើលតុ ទូ ជើងម៉ា ហើយនឹងប្រដាប់សំរាប់បង្រៀន ហើយជួសជុលបន្តិចបន្តួចតាមត្រូវការ គឺលាបថ្នាំក្ដារខៀនបញ្ឈរឲ្យខ្មៅមែនទែន ជួសជុលផ្ទាំងផែនទី ហើយនឹងផ្ទាំងគំនូរក្នុងកន្លែងរៀនជាដើម។

## ជំពូក ១

## ការដែលលោកជាគ្រូបង្រៀនត្រូវធ្វើវេលាមុនចូលរៀន

លោកជាគ្រូត្រូវបង្រៀនកូនសិស្ស តែវិជ្ជាណាដែលលោកចេះខ្លួនលោក ហេតុដូច្នេះត្រូវលោករៀនវិជ្ជាណាៗដែលលោកយកទៅបង្រៀនសិស្សនោះជាមុនប្រយោជន៍នឹងបានជ្រាបច្បាស់សេចក្ដីក្នុងវិជ្ជានោះ ប៉ុន្តែដើម្បីនឹងបានប្រយោជន៍នេះទាំងស្រុងដល់កូនសិស្ស ត្រូវបង្រៀនបែបផ្សេង ៗ តាមរបៀបរៀបចំជាស្រេចទុកជាមុន ។

ហេតុនេះរាល់ថ្ងៃលោកគ្រូបង្រៀនត្រូវជ្រាបថាលោកនឹងបង្រៀនអ្វី

ដល់កូនសិស្សហើយនឹងបង្រៀនយ៉ាងដូចម្ដេច ប្រយោជន៍នឹងបានជ្រាប ហេតុនោះ លោកគ្រូបង្រៀន ត្រូវរៀបចំការបង្រៀន ទុកតាមសេចក្ដីអធិប្បាយខាងលើនេះ ការរៀបចំទុកបង្រៀនត្រូវធ្វើឲ្យរួចស្រេច មុនពេលរៀន ឯការរៀបចំនោះ គឺសរសេររបៀបបង្រៀននៅក្នុងសៀវភៅ ១ សរសេរសេចក្ដីបង្រៀននៅក្ដារខៀនបញ្ជរ១ ប្រមូលរបស់នឹងប្រដាប់មកទុកបង្រៀន ១ ។

## ១ របៀបរៀបចំសរសេរទុកក្នុងសៀវភៅ ។

របៀបរៀបចំសរសេរទុកក្នុងសៀវភៅនេះត្រូវមានសេចក្ដីផ្សេង ៗ ដោយពិតប្រាកដអំពីមេរៀនមួយ ៗ ត្រូវមានការហាត់ហើយនឹងកិច្ចដែលត្រូវធ្វើលើមេរៀនមួយ ៗ នោះផង ។

## ត្រូវរៀបចំមេរៀនដោះដូចម្ដេច

ប្រការ ១— ត្រូវធ្វើតាមរបៀបកំណត់ពេលបង្រៀន ការបង្ខំជាដំបូងដល់លោកគ្រូបង្រៀនគឺត្រូវបង្រៀនតាមរបៀបកំណត់ពេលបង្រៀនមេរៀនមួយ ៗ ត្រូវរៀនតាមបញ្ញត្តដែលកំណត់ទុកដូច្នេះពល់ថ្ងៃបង្រៀន លោកគ្រូបង្រៀនត្រូវដាក់ឈ្មោះថ្ងៃ ខែ ឆ្នាំ ហើយនឹងម៉ោងដែលបង្រៀនវិជ្ជាមួយ ៗ

ប្រការ ២ - ត្រូវដាក់ថាមេរៀន នោះយកពីសៀវភៅ ឬពីទស្សនាវដ្តី ការរៀបចំបង្រៀន ត្រូវយកពីសៀវភៅឬពីទស្សនាវដ្តីពល់ខែ ទស្សនាវដ្តីនេះមានរបៀបបង្រៀនហូរហែមួយអាទិត្យ ៗ រៀងគ្នា លោកគ្រូត្រូវកត់មេរៀនទាំងឡាយដែលតែងតាមរបៀបដោយម៉ត់ចត់នេះមកដាក់ក្នុងសៀវភៅ ។

ប្រការ ៣- ត្រូវកត់របៀបមេរៀនមួយ ៗ ក្នុងសៀវភៅ ។ សេចក្តីនេះជាការសំខាន់ពីព្រោះមិនត្រូវកត់មេរៀនចប់ ទាំងអស់ដាក់ក្នុងសៀវភៅនោះទេ ប៉ុន្តែត្រូវកត់តែសេចក្តីណាដែលជាប្រយោជន៍ ហើយសេចក្តីនោះក៏ត្រូវមានរបៀបរៀបរយហូរហែផង ឯរបៀបរៀបរយនោះមិនដូចគ្នាគ្រប់តែវិជ្ជាទេ លោកនឹងឃើញរបៀបរៀបរយសំរាប់មេរៀនមួយ ៗ នោះក្នុងទស្សនាវដ្តីក្រោយ ៗ ទៀត ។ វេលានេះយើងអធិប្បាយណែនាំតែពីការរួបរួមទាំងអស់ដែលគួរធ្វើតាម ។

១ - គឺត្រូវទទួលអធិប្បាយតែពីប្រយោជន៍មេរៀននោះត្រូវដាក់ឲ្យជាក់ច្បាស់

២- គិតសេចក្តីពិបាកក្នុងមេរៀននោះទុកជាមុន ។

៣ - កត់ពាក្យសួរសំខាន់ ៗ ដែលត្រូវយកទៅសួរ ។

៤ - ដាក់សេចក្តីសង្ខេបបើមានក្នុងមេរៀននោះ ។

៥- ដាក់កិច្ច ឬ ការហាត់ដែលត្រូវធ្វើលើមេរៀននោះ ។

បើកាលណាលោកគ្រូបង្រៀនបានធ្វើរបៀបរៀបចំនេះល្អហើយ លោកនឹងបង្រៀនបានមិនចាំបាច់កាន់សៀវភៅទីនៅដៃឡើយ ។

## របៀបរៀបចំនៅក្ដារខៀនបញ្ឈរ

កាលណាបានធ្វើរបៀបរៀបចំនៅសៀវភៅរួចស្រេចហើយ លោកគ្រូបង្រៀនត្រូវទៅក្នុងកន្លែងរៀនមុនពេលចូលរៀនបន្តិច វេលានោះលោកគ្រូត្រូវសរសេរសេចក្ដីបង្រៀនគឺដូចជាសេចក្ដីមើល ការហាត់ កិច្ចដែលឲ្យកូនសិស្សធ្វើសេចក្ដីចំណោទនព្វន្ត នៅក្ដារខៀនបញ្ឈរមុនពេលកូនសិស្សមកដល់ធ្វើដូច្នេះ លោកគ្រូនឹងបានចំណេញពេលវេលាជាប្រយោជន៍សំខាន់ណាស់ ម្យ៉ាងទៀត នឹងបានជៀសវាងបំបាត់សេចក្ដីដែលកូនសិស្សប្រព្រឹត្តល្មើសខុសនឹងច្បាប់ ហើយនឹងមាត់ឮសន្ធឹកអ៊ូអា ដែលតែងតែមានជាដរាប វេលាលោកគ្រូសរសេរនៅក្ដារខៀនបញ្ឈរកំពុងពេលរៀន ហើយលោកគ្រូបែរខ្នងឲ្យកូនសិស្ស ។ ដើម្បីនឹងឲ្យបានសំរេចប្រយោជន៍ដូចគ្នាទៀត លោកគ្រូបង្រៀនត្រូវត្រៀមសរសេរកិច្ចការទាំងពួងនៅក្ដារខៀនបញ្ឈរក្នុងពេលកូនសិស្សចេញលេង ទុកនឹងបង្រៀនទៅពេលក្រោយទៀត ។

ជំពូ ២

## វេលាកំពុងបង្រៀន

វេលាចូលរៀនហើយ លោកគ្រូបង្រៀនត្រូវបង្ខំសិស្សឲ្យរៀនគ្រប់គ្នា បើលោករវល់បង្រៀនវិជ្ជាអ្វីដល់កូនសិស្សមួយពួក នោះត្រូវឲ្យកូនសិស្សមួយពួកទៀតធ្វើកិច្ចការអ្វីគឺដូចជាការហាត់ឬចម្លងអ្វីមួយ កូនសិស្សមិនត្រូវនៅស្ងៀមឥតធ្វើអ្វីទេ ។

លោកគ្រូបង្រៀនត្រូវត្រួតត្រាមើលកូនសិស្សគ្រប់គ្នា ប៉ុន្តែមិនត្រូវឲ្យដាច់ខាតខានបង្រៀនផង ដូច្នេះលោកគ្រូត្រូវរំពៃវៃណាស់ វេលាកំពុងបង្រៀនលោកគ្រូគិតតែប្រយោជន៍ឲ្យកូនសិស្ស ត្រូវជ្រាបថាកូនសិស្សប្រុងស្តាប់លោកគ្រប់គ្នាឬទេ ដូច្នេះលោកគ្រូចោទសួរកូនសិស្ស ។

ត្រូវសួរដូចម្តេច — ពាក្យសួរយ៉ាងល្អគឺពាក្យសួរយ៉ាងច្បាស់ហើយខ្លីផង លោកគ្រូត្រូវមានវាចាមួយ ៗ យ៉ាងច្បាស់ ៗ ហើយត្រូវចាំឲ្យកូនសិស្សឆ្លើយ លោកគ្រូមិនត្រូវផ្តើមពាក្យឆ្លើយមុនកូនសិស្សទេ កាលណាសួរទៅកូនសិស្សត្រូវទុកឲ្យកូនសិស្សគិតនឹកខំប្រុងប្រយ័ត្ន ហើយរកសេចក្តីទឹងឆ្លើយ ។

យើងនឹងអធិប្បាយអំពីរឿងនេះទៅក្រោយទៀត ។

ល. ម៉ានិពូង៍

ស្រង់ពីកិច្ចសិក្សាបារាំងសែស - ខ្មែរ

ខែដេសមប្រ៍ ឆ្នាំ ១៩៣៣

ន. ឈ.

ឧត្តមដ្ឋាន

# សេចក្តីសម្ពន្ធនឹងគ្នា

មនុស្សយើងនឹងនៅតែម្នាក់ឯងក្នុងលោកនេះមិនបាន ត្រូវតែបងសម្ពន្ធទាក់ទាមគ្នានូវគ្នាទៅវិញទៅមក សេចក្តីសម្ពន្ធនេះឯងបង្គាប់ឲ្យរួមជាពួកតាំងដើមអំពីរួមគ្នាជាគ្រួសារនីមួយ ៗ ឬក្នុងវង់វង្សញាតិនីមួយ ៗ ឡើងទៅដរាបដល់ទៅរួមជាជាតិនីមួយ ៗ ជាទីបំផុត តែជាគ្រួសារវង្សញាតិឬជាតិនោះដែលនឹងតាំងជាមាំមួនអស់កាលជាយូរ ក៏គោងអាស្រ័យមនុស្សដែលរួមជាតិនៅក្នុងប្រទេសជាមួយគ្នាព្រមព្រៀងចិត្តគ្នា ប៉ុន្តែបងបំណងរកសេចក្តីចំរើនមកឲ្យពួក មានគោលដែលបំណងត្រង់ត្រូវគ្នា មានសេចក្តីស្និទ្ធស្នាលស្រឡាញ់រាប់អានគ្នាជាចិត្តមួយ អនុគ្រោះសង្គ្រោះបែកបាយដល់គ្នានូវគ្នាតាមដែលត្រូវការ មានសេចក្តីប្រព្រឹត្តស្មើគ្នារួមកំលាំងផងគ្នាជួយគ្នា រក្សាទំនុកបម្រុងពួករបស់ខ្លួន ចូរមើលតួយ៉ាងពួកដែលគេរុងរឿងហើយៈ គេបាត់ការទំនុកបម្រុងពួករបស់គេឲ្យចំរើនរុងរឿងដោយវិធីយ៉ាងណាខ្លះ ក៏ជួយគ្នានាំយកវិធីការរបស់គេនោះមកប្រៀបធៀបនឹងវិធីការរបស់ខ្លួន ឃើញត្រង់ណាដែលជាការល្អតែខាងយើងនៅខ្វះកន្ទះក៏ជួយគ្នាទំនុកបម្រុងឲ្យបរិបូណ៌ឡើង ត្រង់ណាដែលស្តុកស្តម្ភមាំ-មួនហើយ កជួយគ្នាជ្រោមជ្រែងរក្សាការនោះឲ្យបានឋិតថេរចិរកាលទៅ

ឲ្យមានកិត្តិយសជាអារ្យជាតិអារ្យជនដូចគេទាំងឡាយ ដោយន័យប៉ុណ្ណោះ ល្មមឲ្យឃើញថា សេចក្ដីអាចសមគាមពួកនេះជារបស់ដែលមនុស្សគ្រប់រូបត្រូវតែប្រាថ្នា ដ្បិតពួកគណៈដែលនឹងចំរើនឡើងនឹងទ្រង់គង់នៅជ-ដែល ឬនឹងអាប់ឱនចុះ ក៏ព្រោះមនុស្សអ្នកនៅក្នុងពួកនោះឯង ។

ឧកញ្ញា ទេពពិទូរក្រសេម

(ស្រង់ពីសេចក្ដីសំពង់លោក ប.ឈុំ)

## ពន្យល់ពាក្យ

សម្ពន្ធ ឬ សម្ព័ន្ធ=(ម.ថ.សំព័ន) ការចងភ្ជាប់គ្នា–សាមគ្គី. ។

អនុគ្រោះ=(ស.អនុគ្រហ – ម.អនុគ្គហ) ការជួយទំនុកបំរុង–ករុណា ។

អារ្យ–(ម.ថ.អារយៈ) អារ្យជន ឬអរិយជន គឺជនដែលមានរបៀបបែបបទ
ទំនៀមសណ្ដាប់ល្អប្រសើរនាំឲ្យមានសេចក្ដីចំរើន ។

អាប់ឱនៈ=(ម.ថ.អ័បឱន) គុ. តិចតួច-ស្ដួចស្ដើង-ថោកទាប ។

អក្ខរាវិរុទ្ធៈ គ្រួសារ (រ) វង្ស (ង្ស) យូរ (រ) សិទ្ធ (ទ្ធ) ស្តម្ភ (ម្ភ)
កិត្តិយស (ត្តិ) ។

សួរចោទ·= មនុស្សក្នុងលោកនេះបើកើតមកហើយនៅតែឯកឯងឥតមាន មិត្តភក្តិ តើបានសេចក្ដីប្រសើរចំរើនឬទេ ។ ពីព្រោះអ្វី ? ។

សេចក្ដីសម្ពន្ធមានបែបបទដូចម្ដេចខ្លះ ។

# សេចក្ដីបំណង

ការដែលតាំងខ្លួនបានជាមនុស្សស្ដុកស្ដម្ភម៉ាំមួនឈ្មោះថា អាចសមតាមអត្តភាព ដោយសេចក្ដីស្គាល់ដំឡៃរបស់ខ្លួន មានដើមថា មានជាតិដូចម្ដេចមានត្រកូលដូចម្ដេច មានភេទដូចម្ដេច មានយសស័ក្ដិត្រឹមណាក៏អាចតាំងខ្លួនឲ្យសមតាមនោះ ចាប់ដើមតាំងតែជាអ្នកសុភាពរាបសាតែជាអ្នកអង់អាចក្លាហាន ក្នុងករណីយកិច្ចតូចធំមិនជាក់ធុរៈ ព្យាយាម-ប្រឹងធ្វើទាល់តែសម្រេចមកបាន ៗ មនុស្សដែលទន់ជាបំផុត នឹងមនុស្សដែលរឹងជាបំផុតមិនអាចនឹងតាំងខ្លួនឯងបាន ទើបមិនសមគួរនឹងប្រព្រឹត្តដូច្នោះ សូម្បីក្នុងខណៈធ្វើករណីយកិច្ច ប្រសិនជាមានឧបសគ្គមកជំទាស់ក៏មិនគួរនឹងរអាចិត្តធុញថប់ចុះចាញ់ណាយ ៗ តោងប្រុងប្រយ័ត្នកុំឲ្យខូចការតាំងចិត្តអំណត់ប៉ុនប៉ងធ្វើរឿយ ៗ ទៅកុំឈប់ ត្រូវធ្វើចិត្តឲ្យរីករាយក្នុងសេចក្ដីមិនប្រមាទហើយថ្នមចិត្តនោះ ទុកទាល់តែអាចដកខ្លួនឲ្យផុតឧបសគ្គនោះជាជាន់ ៗ រហូតដល់ជាន់ជាទីបំផុត ប្រៀបដូចជាងទង ដែលឧស្សាហ៍ខាត់ជំរះមន្ទិលមាសឲ្យស្អាតបន្តិចម្ដង ៗ ទាល់តែមាសឡើងពណ៌ក៏ថ្លាគួរប្រើជាគ្រឿងប្រដាប់ដ៏មានដំឡៃ ៗ ដោយន័យនេះមនុស្សដែលសុខចិត្តចាញ់ឧបសគ្គណាយ ៗ ក៏ដូចជាឱបក្រសោបទុក្ខមកទុកក្នុងខ្លួន ទើបសមគួរណាស់នឹងយកចិត្តទុកដាក់សង្កេតមើលការងាររបស់ខ្លួន ដែល

ធ្វើសម្រេចហើយ ឬនៅមិនទាន់សម្រេច កាលឃើញថាមានឧបស័គ្គមកជំពាស់ក៏មិនបានទម្រន់ដាក់ធុរៈរអាចិត្តណាយ ៗ ហើយខំព្យាយាមពុះពាឡើងដល់ផុតទៅបាន ក៏អាចតាំងខ្លួនជាធំបាន រាយពិតប្រាកដ ៗ

ឧកញ៉ាទេពពិទូរ ក្រសេម

(ស្រង់ពីសេចក្ដីសំរាំងលោក ប-ឈុំ)

## ពន្យល់ពាក្យ

ស្តុកស្តម្ភ= (ម. ថ. ស្តំ)= មាំមួន – រឹងដំហរ (ដោយទ្រព្យសម្បត្តិ)

អត្តភាព– (ម. ថ. អ័ត្តតៈ) – អត្ត – ខ្លួន អត្តភាព – ភាវៈរបស់ខ្លួន ៗ

ឧបស័គ្គ– ឧបទ្រព – ចង្រៃ – គ្រឿងជំពាស់ គ្រឿងរាំងដំណើរ

សន្តានពាក្យ: ភ្លឺ – ពន្លឺ – ចំភ្លឺ .....

វេវចនៈ ក្លាហាន – ហ៊ាន – ល្មុះ – មោះមុត អង់អាច ៗ

សទិសសព្ទ: ចិត្ត (ន) ចិត្តល្អ ៗ ចិត (កិ) ចិតបន្លែ ៗ ចិត្រ (ន) ចិត្រមួយភ្លើង (ក្រុកជាតិ) ៗ ចិត្រ (គុ) ពិចិត្រ - វិចិត្រ ៗ

អក្ខរាវិរុទ្ធ: ស្តុកស្តម្ភ (ម្ភ) – កិច្ច (ច្ច) – ប្រមាទ (ទ) – ឧស្សាហ៍

សួរថាៈ— ដែលនឹងតាំងខ្លួនជាមនុស្សស្ដុកស្ដម្ភបានត្រូវប្រព្រឹត្តដូច ម្ដេច ?

មនុស្សយើងត្រូវកាន់ចិត្តដូចម្ដេចនឹងបានឈ្នះឧបសគ្គទាំងឡាយ

---

## មជ្ឈមដ្ឋានទី ២

## សេចក្ដីអាច

សេចក្ដីអាចជួយស្ទួយជីវិត ឲ្យចេះធ្វើ ចេះនិយាយ ចេះគិត តែក្នុងផ្លូវល្អ ដឹងទាន់បុគ្គលនឹងហេតុការណ៍ អាចប្រកបកិច្ចការតូចធំ រាប់តាំងតែថ្នាក់ទាបៗឡើងទៅទាល់ដល់ខ្ពស់ផុតប្រមាណក៏បាន ឲ្យកន្លងផុតឧប-សគ្គជាជាន់ៗទៅ តឿនក្រើនខ្លួនឲ្យប្រព្រឹត្តតែសេចក្ដីល្អស្មើដើមស្មើចុង ។ សេចក្ដីល្អឯណាមិនទាន់មានក្នុងខ្លួន ក៏ញុះចិត្តឲ្យខ្មីឃ្មាតឲ្យប្រព្រឹត្តតែសេចក្ដីល្អយ៉ាងនោះទាល់តែបាន, ចំណែកឯសេចក្ដីល្អដែលប្រព្រឹត្តបានហើយក៏ក្រើនចិត្តឲ្យប្រុងប្រយ័ត្នរក្សាមិនឲ្យប្រែប្រួលថយចុះ មានតែជួញចិត្តឲ្យប្រព្រឹត្តសេចក្ដីល្អទៅឡើងទាល់ផុតសេចក្ដីអាច កាលប្រទះឃើញអ្វីដែលល្អចំឡែក ក៏ជួយជំរុញចិត្តឲ្យយកយ៉ាងតាមនោះ បើដូចជាមានកល្យាណមិត្រចាំខ្សឹបប្រាប់ថា ចូរយកយ៉ាងតាមគំបិលដែលរក្សាសេចក្ដី

ព្រៃរបស់វាទុក    ឬដើមឈើដែលគេរក្សាសេចក្ដីខ្ពស់របស់វាទុកបានដូច្នោះ
បុះ ៗ ដូច្នេះសេចក្ដីល្អដែលប្រព្រឹត្តបានមកហើយនោះ ក៏នឹងឋិតថេរថេរ
កាលទៅយ៉ាងខ្ពស់ ៗ

ឧកញ៉ា ទេពពិទូរ ក្រសេម

(ស្រង់ពីសេចក្ដីសំរាំងលោក ប. ឈុំ)

## ពន្យល់ពាក្យ

សេចក្ដីអាច = សេចក្ដីហ៊ាន - ធ្វើបាន - មិនរួញរា

ការណ៍ = ហេតុ - ដំណើរ

ឧបស័គ្គ = (ម. ជ. អ៊ុប. ស័ក) = គ្រឿងជំពាស់រាំងដំណើរ

យកយ៉ាង = យកបែប - ទំនង - ភាព

កល្យាណមិត្រ = មិត្រដ៏ប្រសើរគួររាប់អាន ៗ

សន្ទានពាក្យ: ទាប = បន្ទាប ៗ

អក្ខរាវិរុទ្ធ: ហេតុការណ៍ (រណ៍) - ឧបស័គ្គ (ស័គ្គ) - គឿន (គ)

កល្យាណ (ណ) - ឋិតថេរ (រ) ៗ

សទិសសព្ទ: ក = កមនុស្ស - កដប - កសាងចេតិយ - កកើតជាក្ដិម ៗ

ក៏ = (និបាតសព្ទ) អ្នកក៏ទៅខ្ញុំក៏ទៅ - សើចក៏ដោយ យំក៏ដោយ ៗ

ករ = (ដៃ) លើកករប្រណម្យ (លើកកំបង់អញ្ជលីសំពះ) ៗ

ករ = កករទឹក–កករប្រេង–កកូរទឹក–កកូរសម្លកកូរ ។

សួរចោទ – សេចក្ដីអាចជួយសួយជីវិតបានយ៉ាងណាខ្លះ ។ សេចក្ដីល្អ ដែលប្រព្រឹត្តបានហើយអាចជួយរំលឹកចិត្តដូចម្ដេចទៀត ។

## សេចក្ដីក្លាហាននៃយុវតីម្នាក់

ខ្យល់បក់ដោយកម្លាំងខ្លាំង សមុទ្រ រញ្ជួយ នោះក្នុងទូកក្ដោងមួយ មាននេសាទម្នាក់ នឹងកូនក្រមុំកូនកម្លោះ អ្នកទាំងនោះប្រឹងបើកក្ដោងដោយរួសរាន់ ដើម្បីនឹងវិលត្រឡប់មកកៀនវិញ ។ ស្រាប់តែឮកញ្ចែបន្ទុំសព្ទ ឯនាយកណ្ដាលលំហសមុទ្រ គឺកញ្ចែកប៉ាល់ចំឡែកមួយស្រែករកតែកុង ដែលអាចនាំចូលទៅក្នុងកៀនបាន ប៉ុន្តែគ្មានអ្នកទូកនាវាណាមួយហ៊ាន ចេញទៅនាំកប៉ាល់នោះសោះ ។ វេលានោះនាងយុវតីស្រដីនឹងឪពុកថា: << ប៉ូឪទៅនាំកប៉ាល់នោះចុះទុកខ្ញុំទៅតែម្នាក់ឯង >> ឪពុកអេះអុញមិនព្រមទៅ យុវតីរបស់គាត់បេះតែតឿន គាត់ក៏ដាច់ចិត្តទៅជួយកប៉ាល់ទើបសំដៅទូកទៅអែបនឹងកប៉ាល់ហើយប្រាប់ឡើង ទុកទូកឲ្យកូនស្រីគាត់បើកក្ដោងខ្លួនឯងទៅកៀន ។ រលកខ្ពស់ៗធំឡើងៗ នោះអ្នកនេសាទឯទៀតប្រមូលគ្នាទៅជ្រកនៅសសរគោមដំរុយប្រឹងសម្លឹងតាំង ដោយសើបនឹងទូកប្ញុងប្រាងគាត់រលក ហើយកាច់បង្កិតដោយក្មេងតូចៗតែពីរនាក់ ។

ទូកចូនផុតដល់គៀន ម្ដាយនាងយុវតីចាំនៅនោះភ័យញ័ររន្ធត់ នាងក្រមុំទៅដល់ត្រើយហើយស្ទុះលោតទៅឱបមាតាដោយអំណរក្រៃលែង ។

លោក ពូវ-អ៊ុំ

(ស្រង់ពីសេចក្ដីសំរាំងលោក ប. ឈុំ)

## ពន្យល់ពាក្យ

យុវតី= (ម.ថ.ដី) ស្រីក្រមុំ

យុវជន= ជនកម្លោះ

ញ័ររន្ធត់= ភ័យស្លុត

វេរបទ:= ខ្យល់-ព្រះពាយ-វាយុ-វាត ។

សទិសសព្ទ: សព្ទ (ន.) សូរសព្ទ-សព្ទ-សព្ទស័ក (ឆ្នាំទី៧)

សាប់ (កិ.) សាប់ទំពាំង ។

កា= កាខ្ចងសំបុត្រ-កាទឹក (បំពង់សម្រាប់ដាក់ទឹក)

កាណ៍= ព្រះកាណ៍ (ត្របៀកស្ដេច)

ការ= ធ្វើការ-ការងារ-ការពារ-ការស្បូត្រ ។

ការណ៍= (ហេតុ,ដំណើរ) ទាស់ការណ៍-មានការណ៍ក្រណាស់ ។

អក្ខរាវិរុទ្ធ: ក្លាហាន (ក្លូ) សមុទ្រ (ទ្រ) គៀន (ក)-សព្ទ (ព្ទ)-គៀន (គ) សសរ (រ)

សួរថា៖– ក្នុងរឿងនេះគេអធិប្បាយពីនាងយុវតីក្នុងគ្រាដូចម្ដេច ។
សេចក្ដីក្លាហានដូចម្ដេចដែលនាងនោះសម្ដែងឲ្យឃើញឡើង ។

---

## មជ្ឈមដ្ឋាន ទី ១

**រៀនមើល – សរសេរតាមសូត្រ**

# រឿងវាយឆ្កែខុស

មានសេដ្ឋីម្នាក់ មានឃ្លាំងមាសឃ្លាំងប្រាក់ច្រើនណាស់ ហើយចិញ្ចឹមឆ្កែកាចប្រាំ ដើម្បីឲ្យនៅចាំរក្សាឃ្លាំងមាសប្រាក់នោះ ។ សម័យថ្ងៃមួយ មានចោរបួននាក់ ជីកទម្លុងរូងដីពីក្រៅកំពែង ហើយចូលតាមរូងនោះ ទៅដល់កណ្ដាលឃ្លាំងមាសឃ្លាំងប្រាក់ ។

ឆ្កែទាំងប្រាំ ធុំក្លិនមនុស្ស ក៏នាំគ្នាចូលទៅខាំចោរក្នុងរូងនោះស្លាប់អស់ទៅ ។ ឯគំនរមាសប្រាក់ក៏ធ្លាក់ស្រុតទៅគ្របលើរូង ។

សេដ្ឋីចូលទៅត្រួតត្រាមើលឃ្លាំងឃើញធ្លាក់ស្រកស្រុត ខុសប្រក្រតីដូច្នោះ ក៏នឹកខឹងនឹងឆ្កែ ហើយបង្គាប់កូនក្មួយឲ្យយកឆ្កែទៅសម្លាប់ចោល

អស់ទៅ ។ លុះដល់ថ្ងៃក្រោយ បានឃើញខ្មោចអាចារ ទើបសេដ្ឋីនឹកស្ដាយស្រណោះឆ្កែទាំងអស់នោះណាស់ ហើយមានវិប្បដិសារីថា៖ "អញវាយឆ្កែខុស" ។

## ពន្យល់ពាក្យ

សេដ្ឋី (អ. ថ. សេតឋី) = អ្នកមានទ្រព្យឧត្ដម, អ្នកមានទ្រព្យច្រើន ។ ឃ្លាំង = ផ្ទះសម្រាប់ទុកដាក់ទ្រព្យរបស់ ។ ឧម្មង្គ = (អ.ថ. អ៊ុំម៉ង់ ឬ តាមទម្លាប់ថា អ៊ុម៉ង់) = រូងដែលជីកលុងក្នុងដីឬក្នុងភ្នំជាផ្លូវដើរបាន ។ ខុសប្រក្រតី = មិនដូចធម្មតា ។ កូនក្មយ = មនុស្សនៅក្នុងបន្ទុកឱ្យចៅហ្វាយនាយ ។ វិប្បដិសារី (អ. ថ. វិបប៉ះដិសារី) = មានសេចក្ដីក្ដៅក្រហាយ, សេចក្ដីនឹកស្ដាយក្រោយ ។

ពាក្យសួរ.– មនុស្សដូចម្ដេចដែលហៅថា សេដ្ឋី? សេដ្ឋីនោះចិញ្ចឹមឆ្កែប៉ុន្មាន? ឆ្កែនោះស្លូតឬកាច? ចិញ្ចឹមទុកដើម្បីអ្វី? ហេតុដូចម្ដេចបានជាសេដ្ឋីឲ្យសម្លាប់ចោល? ដល់ក្រោយមកសេដ្ឋីមានវិប្បដិសារីថាដូចម្ដេច? ។ ព្រោះអ្វី? ។

## អានិកដ្ឋាន

### បង្រៀនពាក្យនឹងភាសា

ពាក្យនឹងភាសា គឺជាវិជ្ជាមួយយ៉ាងវិសេស ដែលបំបែកទៅវិជ្ជាឯទៀត ដូចជាបង្រៀនមើល សរសេរតាមសូត្រ ។ល។

ឯនឹងបង្រៀនពាក្យ មុនដំបូងត្រូវបង្រៀនពាក្យណាដែលងាយ ៗ សិន រួចសឹមបង្រៀនពាក្យពិបាកជាខាងក្រោយ ។

បើបង្រៀន នាម ត្រូវមានរបស់ដែលជា នាម មកបង្ហាញពន្យល់ បើគ្មានរបស់នោះទេ ត្រូវគូររូបបង្ហាញសិស្ស បើមានរូបភាពស្រាប់ ត្រូវចង្អុលបង្ហាញផង ។

បង្រៀន គុណនាម ត្រូវប្រៀបប្រដូចរបស់នោះ ឲ្យឃើញថា តូច-ឬធំ សឬខ្មៅ ល្អឬអាក្រក់ ។ល។

បង្រៀន កិរិយាសព្ទ គឺត្រូវឲ្យសិស្សធ្វើទំនងតាមកិរិយារបស់នោះគឺ ដូចជាបង្គាប់សិស្ស ឲ្យក្រោក ឲ្យឈរ ឲ្យដើរ ឲ្យដូត ឲ្យបិត ។ល។

# អាទិត្យទី ១ .– បង្រៀនពាក្យ

## ១ – អំពីសាលារៀន

នាម សាលារៀន ឆ្នាំសិក្សា សិស្ស ពេលចូលរៀន ពេលសំរាករៀន សាលាសិក្សាវត្ត សាលាបឋមវិជ្ជានៅភូមិ សាលាបំពេញវិជ្ជា សាលាឧត្តមវិជ្ជា សញ្ញាប័ត្រ ។

គុណនាម ថ្មី ចាស់ ល្អ អាក្រក់ ខ្ពស់ ទាប យូរ ឆាប់ ជិត ឆ្ងាយ ខ្ជិល ឧស្សាហ៍ ។

កិរិយាសព្ទ សុំចុះឈ្មោះ ចូលរៀន រៀនបំពេញវិជ្ជា ឈប់សំរាក ឈប់រៀន ឡើងថ្នាក់ ប្រឡង បានសញ្ញាប័ត្រ ។

ហាត់ភាសា ក្នុងមួយឆ្នាំសិក្សា សិស្សរៀនប៉ុន្មានខែ? ឈប់សំរាកប៉ុន្មានខែ? នៅពេលណាដែលសិស្សចូលរៀនជាថ្មី? សាលាដែលរៀនឈ្មោះសាលាអ្វី? (សាលាសិក្សា វត្តឬសាលាបឋមវិជ្ជានៅភូមិ) ។ល។ សិស្សត្រូវធ្វើដូចម្ដេច ដើម្បីឲ្យបានឡើងថ្នាក់? ឲ្យបានប្រឡងជាប់? សិស្សកំជិលបានសម្រេចប្រយោជន៍អ្វីដែរឬទេ?

វិធីហាត់សរសេរ ឲ្យតែងសេចក្ដីជាពាក្យ ឬ ឲ្យបំពេញសេចក្ដី

នៅកន្លែងចន្លោះពងត្រី ដូចខាងក្រោមនេះ

ក្នុងមួយឆ្នាំសិក្សា ……. ( សិស្ស ) មក ….. ( រៀន )…… ( ៩ ខែ ) ឈប់សំរាក ….. ( ៣ ខែ ) ។ ខ្ញុំរៀននៅសាលា…… ( សិក្សាវត្តឬសាលាបឋមវិជ្ជានៅភូមិ ។ល។ ) ខ្ញុំត្រូវ….. ឧស្សាហ៍រៀនសូត្រ ) ដើម្បីឲ្យបានឡើងថ្នាក់ប្រឡងជាប់នៅ….. ពេលដាច់ឆ្នាំ ។

## ២ – សិស្សឧស្សាហ៍រៀនសូត្រ

( សៀវភៅវិជ្ជាខេមរៈភាសាបរិច្ឆណ្ឌនទំព័រ ២៥ ) ។

កែតម្រូវពាក្យក្នុងមេរៀននេះ ៖ គឹត = សរសេរជាគិត ។ មឹន = ជាមិន ។ ត្រិម = ជាត្រឹម ។

សុំឲ្យរើសពាក្យ – នាម – គុណនាម – កិរិយាសព្ទ ដែលមានក្នុងរឿងនេះ ដាក់ឲ្យសិស្សរៀនផង ។

**ហាត់ភាសា** អ្នកត្រូវធ្វើដូចម្ដេចដើម្បីឲ្យបានចេះដឹង? អ្នកស្រឡាញ់ចំណេះវិជ្ជាឬទេ ? ព្រោះអ្វី ? មនុស្សចេះដឹងយ៉ាងដូចម្ដេច ? ចុះមនុស្សល្ងង់ខ្លៅយ៉ាងណាវិញ ? ដល់អ្នកធំឡើងអ្នកចង់ធ្វើអ្វី ? (ចង់ធ្វើនាម៉ឺនឬចង់រកស៊ី ) ហេតុអ្វី ? ។

| បង្រៀនមើល |
|---|

## ១ – ព្រោះអ្វីបានជាខ្ញុំទៅសារៀន

( សៀវភៅវិជ្ជាខេមរៈភាសាបវេច្ចណាដ្ឋាន ទំព័រ ៤ មេរៀនទី ៣ )

ពាក្យពន្យល់ – មិត្តសំឡាញ់ ពតិមាន ផលព្រះធរណី ទូន្មាន លុះដោយគន្លងធម៌ ។

## ២ – សេចក្ដីព្យាយាមនឹងបានសំរេចដូចប្រាថ្នា

(សៀវភៅវិជ្ជាខេមរៈភាសា អាទិកដ្ឋាន ទំព័រ ៨២ មេរៀនទី ៥៥)។

ពាក្យពន្យល់ – សញ្ញាប័ត្រឧត្ដមវិជ្ជា សាលាបឋមវិជ្ជា បាកំងខ្មែរ ដុតបំភ្លឺរៀន សេចក្ដីព្យាយាម ។

## របៀបបង្រៀនមើល

ឲ្យចម្លងសូត្រនេះនៅក្ដារខៀនដោយផ្ចិតផ្ចង់ បើជាសិស្សគ្មានសៀវភៅគ្រប់គ្រាន់ទេ ។

គ្រូត្រូវមើលពាក្យនេះឲ្យសិស្សស្ដាប់ ជាមួយ ៗ ឲ្យច្បាស់ពាក្យ ឬតួអក្សរនោះ ។

គ្រូមើលសូត្រនេះ ឲ្យសិស្សថាតាមពីរឬបីនាក់មុន ឬឲ្យថាតាមព្រមគ្នាទាំងអស់ក៏បាន រួចផ្ដាច់ឲ្យសិស្សម្នាក់មើលឲ្យថាខ្យល់អក្សរឲ្យត្រឹមត្រូវ ។

ពន្យល់ពាក្យពិបាកដែលនៅក្នុងសូត្រ ។

ហៅសិស្សផ្លាស់គ្នាឲ្យមើលសូត្រនេះ កុំហៅសិស្សរៀងគ្នាតាមតុ ។

គ្រូបង្គាប់ឲ្យកែពាក្យសំដីណាដែលសិស្សថាមិនច្បាស់ ។

## សរសេរតាមសូត្រ

សូមលោកគ្រូជ្រើសរើសសេចក្ដីណា ដែលបានបង្រៀន ក្នុងវិធីបង្រៀនពាក្យ ហាត់ភាសា បង្រៀនមើល យកមកបង្រៀនដាក់អក្សរត្រឹមត្រូវផងចុះ តែមិនត្រូវយកពាក្យពិបាកណាមួយ ដែលសិស្សមិនដែលបានឃើញ បានស្គាល់មកឲ្យសរសេរតាមគ្រូថានោះទេ ។

## បង្រៀនដាក់អក្សរត្រឹមត្រូវតាមគ្រូថា

មុនដំបូងត្រូវមើលសូត្រឲ្យសិស្សស្ដាប់ រួចសរសេរពាក្យពិបាកជាបំណាំនៅក្ដារខៀន ហើយពន្យល់ពាក្យនោះផង ។

ឲ្យសិស្សសរសេរពាក្យនោះនៅលើក្ដារខៀនជាច្រើនដង ហើយឲ្យមើលប្រកបពាក្យនោះ រួចហើយលុបចេញ ។

ត្រូវលុបពាក្យដែលសរសេរនៅក្ដារខៀនចោលចេញ ធ្វើបែបនេះដើម្បីឲ្យសិស្សឃើញពាក្យនោះត្រឹមត្រូវ ៖

ក )– ឲ្យសិស្សចំណាំដោយភ្នែកបានឃើញ ។

ខ )– ឲ្យសិស្សសរសេរពាក្យនោះច្រើនដង ដើម្បីឲ្យចំណាំដោយដៃបានគូស - បានសរសេរ ។

ហៅសូត្រឲ្យសិស្សសរសេរតាម ជាមួយ ៗ ហើយឲ្យច្បាស់លាស់ផង គ្រូដើរក្រោយខ្នងសិស្ស ដើម្បីសំគាល់មើលថា ៖ សិស្សនេះសរសេរខុសច្រើន សិស្សនោះសរសេរត្រូវច្រើន ។

គ្រូសរសេរសូត្រនេះនៅក្ដារខៀនម្ដងមួយឃ្លា ៗ ឲ្យសិស្សកែសៀវភៅតាម ពាក្យណាដែលសរសេរខុស ឲ្យវាគូសខ្មៅដៃពីក្រោម ឲ្យសរសេរពាក្យត្រូវពីលើពាក្យខុសនោះ ហើយឲ្យដាក់ចំនួនខុសប៉ុន្មាន ១ ផង ។

គ្រូត្រូវត្រួតមើលដាក់ពិន្ទុឲ្យសិស្សផង ។

ឲ្យសិស្សសរសេរពាក្យដែលខុស ( ខុសមួយម៉ាត់ឲ្យសរសេរមួយបន្ទាត់ ) ។

## អក្សរធំ

យើងត្រូវជ្រើសរើសរកតួអក្សរដែលមានសណ្ឋានប្រហែល ៗ គ្នា មកដាក់ឲ្យសិស្សហាត់សរសេរដូចខាងក្រោមនេះ ៖

ក ភ គ ត ឥ ត្ដៀ

ក កា កឺ កូ កួ កើ កេ កែ កោ កុំ កំ កាំ

កកេរ កកូរ កុំកិកកុក កើតក្ដី កាំភ្លើង

ភ្លាត់កែ ភិតភ័យ កុំភូតភរគេ ត្រីកំភ្លាញ

---

បរិច្ឆណដ្ឋាន

## រៀនពាក្យនិងភាសា

មេរៀនទី ១– ឆ្កែ, ឆ្មា, មាន់, ទា, ក្ងាន, ជ្រូក, ពពែ, ចៀម, គោ, ក្របី, សេះ, ដំរី, ខ្លាដម្បង, ខ្លារខិន, ប្រើស, រមាំង, ក្ដាន់, ទន្សោង, គោព្រៃ, ទន្សាយ, សំពោច, កង្ហែន, ជ្រូកព្រៃ, ស្កា, ពស់, ខ្លាឃ្មុំ, ស្វាក្រោស, ស្វាក្រេះ, បបក, តោច, ឈ្លូះ, កេ, ទន្សង, ពង្រូល, ក្រពើ, ឆ្កែកាប, ឆ្កែ, ស្ទូត, ឆ្មាសាំង, រមាំង, ថ្លាង, ដំរីធំ, មាន់តូប, ទន្សាយលឿនជ្រូកយឺត ;

ឆ្កែខាំ, ឆ្មាក្រចៅ, មាន់ប្រាស, ទាហួរ, ជ្រូកឈ្មុស, សេះផាយ-លុន, ដំរីព្រេច, ក្របីវែ, គោបុះ, ខ្លាសង្គ្រប់, ទន្សាយបោល, ពស់ចឹក, គេមុប

ក្នុងទឹក, ក្រពើហែល, ស្វាលោត, ជ្រូកព្រៃខ្វស, ទន្សងវាំ;

របៀបនឹងបង្រៀន: ត្រូវបង្រៀនហូរហែតាមតារាង កំណត់ចែកវិជ្ជា តាមកម្មវិធី (ប្រូក្រាម) ឲ្យក្មេងបានយល់រហ័ស ចំពោះសត្វស្រុកនឹងសត្វព្រៃ ដែលក្មេងស្គាល់ខ្លះ ៗ ។

របៀបដែលត្រូវបង្រៀនគឺ: បង្ហាញក្មេងឲ្យឃើញសត្វនោះដោយគូរគំនូរនៅលើក្ដារខៀនបញ្ជរ ឬបង្ហាញរូបថតនឹងគំនូរផ្សេង ៗ បើសិនណាជាលែលកនាំសិស្សឲ្យបានឃើញសត្វទាំងនោះជាក់លាក់នឹងភ្នែកជាការប្រសើរណាស់ ។

ត្រង់កិច្ចពន្យល់គុណនាមនឹងកិរិយាត្រូវប្រើឧបាយណា ដែលនាំឲ្យសិស្សបានយល់ជាក់ច្បាស់ -ឧបមា ដូចជា: កាច នឹងស្លូត ត្រូវពន្យល់ឲ្យជាក់ច្បាស់ថា ឆ្កែកាច ព្រុសស្កុះ ដេញខាំ ឆ្កែស្លូតគេដើរទៅជិតអង្អែលក្បាលបាន ។

សេះប្រាយ ត្រូវពន្យល់ដោយធ្វើកិរិយានៅមុខសិស្សដើម្បីឲ្យសិស្សថាសេះប្រាយ គឺសេះដែលធាក់ជើងទៅក្រោយ ។

សូមឲ្យចាំច្បាស់ថា ក្នុងមួយពេល ៗ ឲ្យបង្រៀនត្រឹមតែ ៧ ពាក្យ គឺ នាម ៣ គុណនាម២ កិរិយា ២ ពាក្យនិមួយ ៗ ត្រូវបញ្ចូលក្នុងឃ្លា ។

# មេរៀនទី ១

ផ្លែ, ឆ្មា, មាន់, ទា, កាប, ស្ទូត, ព្រុស, ឆ្មាក្រពៅ;

របៀបបង្រៀន គ្រូបង្ហាញផ្លែឬរូបផ្លែ ទើបចោទសួរសិស្សថា "នេះសត្វអ្វី?" ឆ្លើយម្ដងម្នាក់ ទើបឲ្យក្មេងតែងឃ្លា បើក្មេងតែងមិនកើត ត្រូវចោទសួរឲ្យសិស្សឆ្លើយជាឃ្លា ៗ ណាដែលប្រសើរជាងគេ គ្រូសរសេរទុកលើក្ដារខៀនបញ្ឈរ គ្រូត្រូវឲ្យសិស្សប្រុងប្រយ័ត្នទឹងការសរសេរពាក្យថា "ផ្លែនេះ ឲ្យសិស្សថាដោយមាត់ទទេ ហើយទឹងសរសេរលើក្ដារឆ្នួន

របៀបបង្រៀនពាក្យឯទៀតក៏ដូច្នេះដែរ

## រៀនមើល

អាទិត្យទី ១ នឹងទី ២

១– កូនសិស្សឧស្សាហ៍រៀនសូត្រ (សៀវភៅបវរ. ទំព័រ ២៥)

២– កូនសិស្សខ្ជិល (សៀវភៅដដែលទំព័រ ២៦)

៣– ត្រូវតែរៀនដំរិះវិជ្ជា (សៀវភៅដដែលទំព័រ ៦១)

សុំឲ្យកែពាក្យខុស សូត្រជាសូត្រ គិតជាគិត មិនជាមិន ត្រឹមជាត្រឹម (ទំព័រ ២៥) ខ្ជិលជាខ្ជិល កិរិយាជាកិរិយា (ទំព័រ ២៦) ។

## អាទិត្យទី ៣ ថ្ងៃទី ៤

១- ជម្ងឺគមរមាស់ (សៀវភៅដដែលទំព័រ ២២-២៣)

២- ជម្ងឺគមរមាស់ (ត) (ទំព័រ ២៤-២៥)

៣- ត្រូវថែទាំសំលៀកបំពាក់ (សៀវភៅដដែលទំព័រ ៧៦)

## សរសេរតាមសូត្រ

១- កូនសិស្សឧស្សាហ៍រៀនសូត្រ (ក្ដីមេរៀនមើល)

២- កូនសិស្សខ្ជិល (សៀវភៅដដែលទំព័រ ២៦ ដល់រឿយ ៗ)

៣- កូនសិស្សខ្ជិល (ត) ដល់ចប់

### ឆ្កែខ្ញុំ

ខ្ញុំចិញ្ចឹមឆ្កែមួយ ខ្ញុំដាក់ឈ្មោះវាអាកេ ព្រោះវាមានពណ៌ប្រផេះដូចកេ អាកេឆ្កែខ្ញុំពូជឆ្កែបារាំង មុខក្រញូវមាត់ធំ ស្លឹកត្រចៀកធ្លាក់ កន្ទុយកំបុត រោមវែងៗ ដើរមាំ ក្រចកស្រួច អាកេជាឆ្កែចាំផ្ទះ ។

អាកេចេះណាស់ កាលណាខ្ញុំទៅរៀនវារត់តាមខ្ញុំរាល់តែជិតដល់

សាលា ទើបវាត្រឡប់ទៅផ្ទះវិញ វាដឹងមោនខ្ញុំចេញពីរៀន វាឈរចាំខ្ញុំនៅមុខផ្ទះ កាលណាវាឃើញខ្ញុំ វាស្ទុះលោតកន្ត្រាងលិតដៃជើងខ្ញុំ

ខ្ញុំស្រឡាញ់វាណាស់ ខ្ញុំមិនដែលធ្វើបាបវាទេ ។

---

## កុមារដ្ឋាន

### រៀនពាក្យនិងភាសា

អាទិត្យទី ១ និងទី ២ វត្ថុនៅក្នុងកន្លែងរៀន

ត្រូវរើសស្រង់យកតែពាក្យណាដែលងាយស្រួល គួរក្មេងអាចនឹងយល់បានរហ័ស ។

ពាក្យ ដីស, ក្តារឆ្នួន, ក្តារខៀនបញ្ឈរ, ដងប៉ាកកា, ខ្មៅដៃ, ទឹកខ្មៅ, កំណាត់សំពត់, បន្ទាត់, ផែនទី, គំនូរ, ផ្ទាំងគំនូរ, ផ្ទាំងច្បាប់អក្សរ, តារាងប្រក្រតិទិន, តារាងកំណត់ពេលរៀន, ផ្ទាំងរបៀបរៀនតាមខែ ។

ដីសស, ក្តារឆ្នួនខ្មៅ, ខ្មៅដៃស្រួយ, ទឹកខ្មៅស្វាយ, ក្រដាសព័ណ៌ក្រហម, កំណាត់សំពត់កខ្វក់ បន្ទាត់វែង បន្ទាត់ខ្លី គំនូរតូច ៗ ផ្ទាំងគំនូរធំ ៗ សៀវភៅក្រាស់ ក្រដាសស្តើង ក្តារឆ្នួនរលីង ក្តារខៀនគគ្រាត

ស្លាបប៉ាកកាស្រួច ដងប៉ាកកាទាល បន្ទាត់ត្រង់ រំពត់វៀច ខ្មៅដៃមូល បន្ទាត់សំប៉ែត

សរសេរអក្សរ លុបក្ដារខៀន ចិតខ្មៅដៃ គូរគំនូរ គូសបន្ទាត់ បង្អុលផែនទី មើលអក្សរ លើកក្ដារខៀន ដាក់ក្ដារខៀន

## របៀបបង្រៀន

១ – គ្រូត្រូវរកវត្ថុដើម្បីនឹងបង្ហាញសិស្ស

២– គ្រូបង្រៀនតែ ៧-៨ ពាក្យក្នុងមួយពេល គឺនាម ៣ ឬ ៤ គុណនាម ២ កិរិយា ២ ៗ

មេរៀនទី ១ ដីស ក្ដារខៀន ក្ដារខៀនបញ្ឈរ កំណាត់សំពត់ ដីសស ក្ដារខៀនខ្មៅ សរសេរអក្សរ លុបក្ដារខៀន ៗ

ដើម្បីនឹងបង្រៀន ដីស គ្រូលើកដីស១ដុំបង្ហាញសិស្ស ចោទសួរថា „នេះគឺអ្វី ? ដីសមានសភាពយ៉ាងណា ? តើមានដីសមានទ្រង់ទ្រាយខុសពីនេះទេ ? ទ្រង់ទ្រាយយ៉ាងណាខ្លះ ? អ្នកណាតែងទិញដីស ? មួយដុំថ្លៃប៉ុន្មាន មួយប្រអប់ថ្លៃប៉ុន្មាន ? ដីសសំរាប់ប្រើការយ៉ាងណា ?

ឯពន្យល់ពណ៌ត្រូវយកពណ៌ខ្មៅនឹងសទៅផ្ទឹមគ្នា ដើម្បីឲ្យសិស្សស្គាល់ពាក្យទាំងពីរនេះឲ្យជាក់ច្បាស់

គ្រូពន្យល់កិរិយាសព្ទ ដោយធ្វើកិច្ចនៅមុខសិស្ស ហើយនឹងឲ្យសិស្សធ្វើកិច្ចនោះថែមទៀត ព្រមទាំងចោទសួរ តាមរបៀប ។

## អាទិត្យទី ៣ និងទី ៤

ពាក្យ តុគ្រូ កៅអី ថតតុ ជើងតុ តុសិស្ស ជើងម៉ា ដប ទឹកខ្មៅ ទូ កញ្ចក់ទូ អំបោស ចង្កៀង ផ្ទិត ដៃកៃវ សារមន្ទីរសិក្សា សៀវភៅមើល សៀវភៅសរសេរ ជ័រលុប ប៉្ចាក់ស្បែក

រលោង, រលើប, ស្រអាប់, ថ្មី, ចាស់, រលុង, ភ្ជុយ, សឹក, រិល, ហូត, ដក, ដូត,, ដុស, សំអាត, បោស, ប្រយ័ត្នទុក;

## អាទិត្យទី ៥

ពាក្យ សៀវភៅនព្វន្ត សៀវវត្តស្វាធ្យាយន៍ សៀវភៅភូមិសាស្ត្រ វចនានុក្រម សៀវភៅកម្ពុជាវិតារក្រដាស ក្រដាសប្តិត ជ័រលុប បន្ទាត់ ស្លាបប៉ាកកា ក្របសៀវភៅ ។

ស្តើង ក្រាស់ ថ្មី ទក់ រហែក ទន់ រឹង ភ្ជុះ ដាម

ដាក់ក្រប អានពាក្យ ទន្ទេញ បើកសៀវភៅ

គូសបន្ទាត់ លុប ដុស សូត្រ ស្វាធ្យាយន៍ ផ្តិតទឹកខ្មៅ

សេចក្តីបំភ្លឺ ត្រូវគ្រូរៀបបង្រៀនឲ្យរៀនតាម តារាងកំណត់ពេល

រៀន ( ប្រូក្រាម ) ពាក្យដែលចុះក្នុងសៀវភៅមិនសូវគ្រប់គ្រាន់ គ្រូ លោកគ្រូគបន្ថែមទៀត

## រៀនមើលសរសេរ

### អំពីស្រះ

| | | |
|---|---|---|
| មេរៀនទី ១ | មេរៀនទី ២ | មេរៀនទី ៣ |
| អ អា | អិ អី | អឹ អឺ |
| មេរៀន ៤ | មេរៀនទី ៥ | មេរៀនទី ៦ |
| អុ អូ អួ | អើ អៀ អឿ អេ | អែ អៃ អោ អៅ |
| មេរៀនទី ៧ | | មេរៀនទី ៨ |
| អុំ អំ អាំ អះ | | អុះ អេះ អោះ |

### មេរៀនទី ៩

អី អេ អៅ អុំ អែ អួ អៀ អើ ។ អាអំ អាអាំ អេះអុះ ។ អាអុំអេះអី ។ អាអាំអុំអី ។

កាលណាបើបង្រៀនស្រះខាងលើនេះរួចហើយ គ្រូត្រូវលុបតួ ( អ ) ចេញ ដើម្បីឲ្យនៅតែស្រះនិស្ស័យ ៗ គ្រូត្រូវហ្វឹកហ្វឺនសិស្សឲ្យចេះអាន

ស្រៈនិស្ស័យទាំងអស់ជាប្រាកដ

## មេរៀនទី ១០ ស្រៈនិស្ស័យ

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ
ំ ាំ ះ ុះ

ឯពាក្យដែលបង្រៀនទាំងប៉ុន្មាន កុំមួយពេល ៗ គ្រូសរសេរម្ដងៗ នៅលើក្ដារខៀន ។ ឲ្យសិស្សអានពាក្យទាំងអស់ម្នាក់ម្ដង មួយពួកម្ដង ម្នាក់ម្ដងរួចឲ្យអានពាក្យដែលផ្សំបាននឹងអក្សរដែលយកមកបង្រៀន ។

## មេរៀនទី ១១

ក– គ្រូសរសេរអក្សរ ក លើក្ដារខៀនបញ្ឈរ ប្រាប់ឲ្យប្រុងមើល របៀបសរសេរអក្សរនេះ នឹងសភាពអក្សរនេះ

– រួចហើយគ្រូអានយ៉ាងច្បាស់

– ឲ្យសិស្សអានម្ដងម្នាក់ហើយដោយពួក

– ឲ្យសិស្សសរសេរបង្ហើរតាមខ្យល់

– ឲ្យសិស្សឡើងសរសេរម្ដងម្នាក់នៅក្ដារខៀនបញ្ឈរហើយអានឲ្យច្បាស់ ។

– បើមានខុសគ្រូកែភ្លាម ។

- ឲ្យសិស្សសរសេរទាំងអស់គ្នាលើក្ដារខ្មៀន
- ឲ្យសិស្សលើកក្ដារខ្មៀន បើមានខុសកែភ្លាម ៗ
- ឲ្យអានម្ដងម្នាក់យ៉ាងច្បាស់

ដើម្បីឲ្យសិស្សចាំសម្លេង ក ឲ្យច្បាស់ គ្រូបញ្ចប់មេរៀននេះដោយឲ្យ សិស្សអាន កកាយដី កកូរទឹក កកេះតុះ ៗ

## មេរៀនទី ១២

### ក ផ្សំនឹងស្រះនិស្ស័យ

គ្រូត្រូវប្រើក្រដាសបួនជ្រុងទ្រវែង ( ហៅជាលែត្រម៉ូបិល ) ដូចមាន គំរូនៅក្នុងទស្សនាវដ្ដីលេខ ១ ឆ្នាំសិក្សា ១៩៥១ ១៩៥២ ទំព័រទី ៣-៤-៥

របៀបប្រើ ( លែត្រម៉ូលិស ) នេះក៏ត្រូវមើលក្នុងសៀវភៅនេះដែរ

គ្រូបង្ហាញស្រះមួយ សួរសិស្សអាន

គ្រូយកអក្សរ ក ទៅផ្សំនឹងស្រះនេះ សួរឲ្យសិស្សអាន

រួចឲ្យសិស្សអានម្នាក់ម្ដង ៗ ហើយដោយពួក

គ្រូសរសេរពាក្យនេះយ៉ាងច្បាស់នៅលើក្ដារខៀនបញ្ឈរ

ឲ្យសិស្សសរសេរនៅលើក្ដារខ្មៀន

ឲ្យសិស្សសរសេរលើក្ដារ កែភ្លាម

កី កើ កៃ កោ កិ

## មេរៀនទី ១៣

ក) ផ្សំនឹងស្រៈ ( ត ) ព្រោះយើងទើបនឹងចាប់បង្រៀន ត្រូវយើងកុំទៅល្បឿនពេក មើលតើក្មេងកម្លាំងប៉ុន្មាន ត្រូវដើរតាមកម្លាំងក្មេង កុំបង្ខំក្មេងឲ្យរត់តាមយើង វារត់តាមមិនទាន់ទេ

កា កេ កៀ កឿ កុំ កះ

## មេរៀនទី ១៤

កំ. កាំ កូ កួ កៃ កកូ ( រ ) កកេ ( រ ) កកេះ

## មេរៀនទី

បង្រៀនសាឡើងវិញ ដើម្បីឲ្យប្រាកដជាក្មេងចេះចាំ

អាកៅកកេរ អាកៃកកេះ កឺ កើ កោ កួ កុំ កាំ កំ កះ កឺ កឹ កា

របៀបបង្រៀន គ្រូបង្អុលអក្សរបង្គាប់សិស្សម្នាក់ឲ្យអាន បើវាអានមិនត្រូវ ៗ ឲ្យសិស្សឯទៀតអាន គ្រូអានបង្គាប់ឲ្យសិស្សសរសេរលើក្តារខៀន ហើយអានតាមពួក

## មេរៀនទី ១៥

គ) របៀបបង្រៀនដូចមុន ប៉ុន្តែបើក្មេងចាំស្រៈច្បាស់ហើយ ដើរ

បានលឿន នោះការបង្រៀនក៏អាចនឹងទៅលឿនបាន គ្រូផ្សំជាពាក្យតូច ៗ គាកោកកេះគុះ គាកែគគេះគគះ គាគោកក្លូរគី កោរគី គេគោ ៗ

បង្រៀនតទៅទៀតមើលតារាងកំណត់ចែកវិជ្ជា ( ប្រូក្រាម ) នឹងទស្សនាវដ្ដីលេខ ១ ឆ្នាំសិក្សា ១៩៥១-១៩៥២ ត្រូវរៀបចំបង្រៀនឲ្យហូរហែតាមប្រកបដោយតួព្យញ្ជនៈ មានសភាពប្រហែលគ្នា នឹងមានសម្លេងប្រហែលគ្នា ត្រូវលៃពីស្រួលទៅពិបាក

## តែងសេចក្ដី

សំរាប់

ប្រថមកុមបំពេញវិជ្ជា

កម្មវិធីសំរាប់ខែ - ការរៀបរាប់អំពីវត្ថុ - ការធ្វើពិពណ៌នាអំពីវត្ថុការរៀបរាប់និងការធ្វើពិពណ៌នាអំពីវត្ថុ ៗ

### ១- ការរៀបរាប់អំពីវត្ថុ

ចូរអ្នករៀបរាប់អំពីរបស់ផ្សេង ៗ ដែលមាននៅក្នុងបន្ទប់រៀនអ្នក ៗ

ការរៀបចំ- បន្ទប់រៀនអ្នកតាំងនៅកន្លែងណា ? កាលណាគេចូលមក គេឃើញអ្វីខ្លះ? តុលោកគ្រូដាក់នៅកន្លែងណា? នៅខាងក្រោយ

ជិតតុគ្រូ មានអ្វី ? - នៅតាមជញ្ជាំងមានអ្វី ? នៅខាងឆ្វេង ខាងស្តាំតុគ្រូមានអ្វី? គេឃើញមានអ្វី ? នៅខាងមុខតុគ្រូ ?តុសិស្សនឹងជើងម៉ាតម្រៀបគ្នាដូចម្តេច ? ទាំងអស់មានប៉ុន្មាន ? មានអ្វីនៅតាមជញ្ជាំង ?- ខាងស្តាំ ? ខាងឆ្វេង ?- ខាងក្រោយតុសិស្ស ? របស់ទាំងនេះមានប្រយោជន៍អ្វី ? គេអាចផ្តុំរបស់ទាំងនេះជាក្រុមតាមប្រយោជន៍របស់វាបានឬទេ ? អ្នកស្រឡាញ់របស់ទាំងនេះឬទេ ? ហេតុអ្វី?

## គោលសេចក្តី

១- ទីកន្លែងបន្ទប់រៀន ។

២- របស់ដែលគេឃើញកាលគេចូលក្នុងបន្ទប់ ៖

ក សំរាប់គ្រូ ៖ តុ ឈើកំណាល់ កៅអី ។

ខ- សំរាប់ សិស្ស ៖ តុ ជើងម៉ា (ចំនួន របៀបតម្រៀប) ។

៣- របស់សំរាប់បង្រៀន ៖ ក្តារខៀន ផ្ទាំងគំនូររង្វាស់រង្វាល់ ដែនទី ភូគោល បន្ទះសុភាសិត...។

៤- របស់សំរាប់លំអថ្នាក់ ៖ ផ្ទាំងរូបភាពផ្សេងៗ ផ្ទាំងគំនូរផ្សេងៗ

៥- យោបល់ ៖ របស់ទាំងនេះសុទ្ធសឹងមានប្រយោជន៍ឬល្អមើល នាំឲ្យខ្ញុំបាទមានចិត្តត្រេកត្រអាលនឹងមកកាន់សាលារៀន ។

## ២= ការធ្វើពិព័ណ៌នាអំពីវត្ថុ

ចូរអ្នកធ្វើពិព័ណ៌នាអំពីតុលោកគ្រូរបស់អ្នក ។

ការរៀបចំ– តុលោកគ្រូដាក់នៅកន្លែងណាក្នុងបន្ទប់រៀន - ហេតុអ្វីបានជាគ្រូដាក់ត្រង់នេះ? តុនោះដំកល់នៅលើអ្វី? ធំឬតូច? ព័ណ៌អ្វី? រាងដូចម្តេច?- មានជើងប៉ុន្មាន? - រាងដូចម្តេច? ធ្វើអំពីឈើអ្វី?

ចូរពិនិត្យមើលផ្ទាំងខាងលើ ៖ មានក្តារប៉ុន្មានសន្លឹក? រលីង ឬគគ្រើម?- ជាផ្ទៃស្មើឬដូចម្តេច? ជ្រុងជុំវិញមានសណ្ឋានបែបណា?- មានថតប៉ុន្មាន? នៅចន្លោះថតទាំងពីរមានអ្វី?- ប្រយោជន៍អ្វី?

គេឃើញមានអ្វីខ្លះនៅលើតុ? (សៀវភៅមើលសរសេរ – ហៅឈ្មោះសិស្ស - ស្រង់ពិន្ទុ ដបទឹកខ្មៅ (ប្រអប់ដីស បន្ទាត់ ។ល។) របស់ទាំងនេះមានកន្លែងរៀងខ្លួនឬទេ?- មានប្រយោជន៍អ្វី?

តុនេះមានប្រយោជន៍ដល់អ្នកណា?

### គោលសេចក្តី

១– កន្លែងតុនៅក្នុងបន្ទប់រៀន ។

២– ទិដ្ឋភាពទាំងមូល ៖ ធំឬតូច? រាង ព័ណ៌ ធ្វើអំពីឈើអ្វី ។

៣– ចំណែកផ្សេងៗ ៖ ខាងលើ ចំហៀង ថត... ។

៤- ផលប្រយោជន៍ ។

## ៣- ការរៀបរាប់និងការធ្វើពិពណ៌នាអំពីវត្ថុ

អ្នកបានទិញកាំបិតបត់មួយសំរាប់ប្រើការ ចូរអ្នកធ្វើពិពណ៌នាអំពី-
កាំបិតនោះ ។

### គោលសេចក្តី

| | |
|---|---|
| | ១ សេចក្តីផ្តើម ។ |
| តួសេចក្តី | ២- ការធ្វើពិពណ៌នាអំពីផ្ទៃ ។ |
| | ៣- ការធ្វើពិពណ៌នាអំពីផ្នែក ។ |
| | ៤- ប្រយោជន៍ ។ |
| | ៥- សេចក្តីបញ្ចប់ ។ |

### សេចក្តីអធិប្បាយ

កាលពីបវេសនកាលមុននេះ ខ្ញុំបាទបានទិញកាំបិតបត់មួយដើម្បីបំពេញចំនួនឧបករណ៍សំរាប់ប្រើក្នុងការសិក្សា ។

កាំបិតនោះមានពីរចំណែក គឺផ្ទៃនិងដងំ ។

ផ្ទៃជាបន្ទះដែកថែបសមួយបន្ទះពនឹបួនជ្រុងទ្រវែងស្រួចចុងហើយ

មានពន្លឺភ្លឺផ្ទុះមុខបាន ។ ចំណែកផ្លែខាងលើមានកំពស់ពីរមិល្លីម៉ែត្រ គឺខ្នងកាំបិត ។ ចំណែកខាងក្រោមស្តើងហើយមុតក្រៃលែង គឺមុខកាំបិត ។ មានបន្ទះមួយប្រវែងមួយសង្ទីម៉ែត្រនៅជិតចុងផ្លែអាចឲ្យខ្ញុំបាទបើកផ្លែចេញពីក្នុងដងបានយ៉ាងងាយដោយបញ្ចូលចុងក្រចកមេដៃទៅក្នុងបន្ទះនោះ ។ នៅខាងគល់ផ្លែមានចារឹកអក្សរបារាំងជាពាក្យថា “ ដែកថែបពុំចេះច្រេះ ” ។ អក្សរទាំងនេះធ្លាក់វង់លើរូបសត្វខ្លែងហើរមួយដែលជាត្រាសញ្ញារបស់ហាងធ្វើកាំបិតនេះ ។

ផ្លែត្រូវភ្ជាប់ទៅនឹងដងដោយគន្លុះដែកមួយ ដើម្បីឲ្យបង្វិលផ្លែបានយ៉ាងស្រួល ។ ដងក៏ធ្វើអំពីដែកសក្លីដែរ គឺជាបន្ទះដែកពីរសន្ទឹកដុះចេញពីសងខាងផ្លែទៅដ៏មានទទឹងនឹងបណ្តោយស្មើនឹងផ្លែដែរ ។ ខ្នងនិងគល់នៃដងត្រូវក្តិតដោយបន្ទះដែករស់ដែលជាគន្លិះសំរាប់ទប់ផ្លែកាំបិត ឲ្យបានរឹងប៉ឹងនៅពេលដែលផ្លែនោះលាតឬបត់ចូលទៅក្នុងដង ។ នៅខាងគល់ដងមានក្រវិលស្ពាន់មួយ ។

ខ្ញុំបាទត្រូវការប្រើកាំបិតនេះក្នុងកិច្ចសិក្សាជាញឹកញាប់ណាស់ ។ ស្ទើរតែរាល់ថ្ងៃ ខ្ញុំបាទចិតខ្មៅដៃដោយកាំបិត ។ ខ្ញុំបាទប្រើកាំបិតជួសជ័រលុបក្នុងកិច្ចកោសកែពាក្យណាដែលសរសេរដោយទឹកខ្មៅទៅខុសទំនងព្រោះបានស្អាតជាង ។ នៅពេលធ្វើការហត្ថកម្មផ្សេង ៗ ខ្ញុំបាទតោង

ប្រើកាំបិតដើម្បីកាត់ក្រដាសពណ៌ ឬក្រដាសក្រាស់ឬបិតឬស្បីផ្សំធ្វើជារបស់ផ្សេងៗ ។ ក្របគដែននឹងក្របកដើង ខ្ញុំបាទបានស្អាតជានិច្ចដោយសារកាំបិតនេះ ។ ឯគូកនខ្ញុំបាទជាច្រើននាក់ក៏បានទាញប្រយោជន៍ពីកាំបិតនេះដែរ ។

ហេតុនេះបានជាខ្ញុំបាទខំថែរក្សាកាំបិតនេះឲ្យបានគង់ចិតថេរតទៅ ដោយខ្ញុំបាទមានខ្សែស្ពាន់ជ្រលក់សំមួយខ្សែសំរាប់ភ្ជាប់កាំបិតនេះត្រង់ក្រវិលមកនឹងខ្សែបង្កេះខោខ្ញុំបាទ ។ ម្យ៉ាងទៀត នៅគ្រប់ពេលដែលខ្ញុំបាទបំពេញកិច្ចការរួច ខ្ញុំបាទពុំដែលភ្លេចប្រមូលប្រដាប់ប្រដា របស់ខ្ញុំបាទទុកឡើយ ។

---

អានិកាដ្ឋាន

## តែងសបក្តី

លំនាំ.– ថ្ងៃនេះក្នុងការតែងសេចក្តីសូមលោកគ្រូដាក់ពាក្យ ៥ ឬ ៦ ពាក្យមាន ( នាម, គុណនាមនឹងកិរិយាស័ព្ទ ) ឲ្យសិស្សតែងជាឃ្លា ( ពាក្យមួយធ្វើឃ្លាមួយ ) ។ លុះសិស្ស

យកពាក្យនិមួយ ៗ ដែលដាក់ឲ្យតែងជាឃ្លារួចហើយនោះទើងកើតបានជារឿងតែងមួយនិយាយអំពីវត្ថុដែលគ្រូប្រាថ្នាឲ្យសិស្សពណ៌នា ៗ

សេចក្ដីតែងទី ១– ចូរអធិប្បាយអំពីខ្លួនមនុស្សដោយធ្វើឃ្លាជាមួយនឹងពាក្យខាងក្រោមនេះ ៗ

ចំណែក- ក្បាល អវយវៈ ស្អាត ដើរ ធ្វើការ ៗ

វិធីហាត់មាត់ទទេ – ខ្លួនមនុស្សចែកជាប៉ុន្មានចំណែក? នៅលើក្បាលមានដុះអ្វី? អ្វីខ្លះដែលហៅថាអវយវៈ? ជើងសំកប់ធ្វើអ្វី? ដៃសំកប់ធ្វើអ្វី? អ្នកត្រូវធ្វើដូចម្ដេចដើម្បីឲ្យបានសុខសប្បាយខ្លួន?

## សេចក្ដីតែងជាគំរូ

ចំណែក = ខ្លួនមនុស្សចែកជាបីចំណែក ៗ

ក្បាល = នៅលើក្បាលមានដុះសក់ ៗ

អវយវៈ = អវយវៈមានពីរយ៉ាងគឺដៃនឹងជើង ៗ

ដើរ = ជើងសំកប់ដើរ ៗ

ធ្វើការ = ដៃសំកប់ធ្វើការ ៗ

ស្អាត = យើងត្រូវងូតទឹកដុសលាងខ្លួនឲ្យស្អាតទើបបានសុខសប្បាយ ៗ

## សេចក្តីតែងទី ២- អំពីវិញ្ញាណប្រាំ

សូមគ្រូរៀបចំរឿងតែងនេះ

## សេចក្តីតែងទី ៣- ចូរអធិប្បាយអំពីបសុសត្វ ( សត្វទាំងឡាយដែលគេចិញ្ចឹម ) ដោយធ្វើឃ្លាជាមួយនឹងពាក្យខាងក្រោមនេះ

សត្វពាហនៈ ប្រយោជន៍- ធ្វើបាប- ចិញ្ចឹម

វិធីហាត់មាត់ទទេ- សត្វទាំងឡាយដែលមនុស្សចិញ្ចឹមហៅថាអ្វី ?

( បសុសត្វ ) ។ សត្វណាខ្លះដែលហៅថាសត្វពាហនៈ ?

បសុសត្វទាំងឡាយមានប្រយោជន៍ដល់មនុស្សយ៉ាងណាខ្លះ ?

ហេតុអ្វីបានជាយើងពុំត្រូវធ្វើបាបសត្វពាហនៈ ?

ហេតុអ្វីបានជាយើងត្រូវចិញ្ចឹមវាដោយល្អ ?

## សេចក្តីតែងជាគំរូ

សត្វពាហនៈ= សត្វពាហនៈដែលយើងប្រើសព្វថ្ងៃ គឺ គោ, ក្របី, សេះ, ដំរី (ល) ។

ប្រយោជន៍= សត្វបំរើទាំងនេះមានប្រយោជន៍ណាស់ គឺសំរាប់អូសរទេះ អូសនង្គ័លនឹងធ្វើជាជំនិះ ។

ធ្វើបាប= យើងពុំត្រូវធ្វើបាបសត្វបំរើទេ ។

ចិញ្ចឹម= យើងត្រូវចិញ្ចឹមវាដោយល្អ ។

## សេចក្ដីតែងទី ៤

អំពីចាណាក់ជាតិ

សូមលោកគ្រូរៀបបំរឿងតែងនេះ

---

បរិច្ឆណដ្ឋាន

## តែងសេចក្ដី

### សរុបរឿង: អំពីសាលារៀន

លំនាំ.- ការតែងសេចក្ដីនៅបរិច្ឆណដ្ឋានត្រូវធ្វើទៅតាមសរុបរឿងនៃការរៀនពាក្យទាំងមូល ។ ដំបូងត្រូវហ្វឹកហ្វឺនសិស្សឲ្យឆ្លើយដោយមាត់ទទេសិនទើបដាក់ការហាត់សរសេរឲ្យធ្វើ ។

សេចក្ដីតែងទី ១

### អំពីសាលារៀនអ្នក

វិធីឆ្លើយមាត់ទទេ.- សាលារៀនអ្នកឈ្មោះអ្វី ? សង់នៅកន្លែង

ណា ? មានថ្នាក់រៀនប៉ុន្មាន ? នៅមុខសាលារៀនមានអ្វី ? អ្នកស្រឡាញ់សាលារៀនអ្នកឬទេ ? ពីព្រោះអ្វី ?

វិធីហាត់សរសេរ.- ចូររើសរកពាក្យត្រឹមត្រូវមកដាក់បំពេញចន្លោះក្នុងឃ្លាខាងក្រោមនេះ ។

សាលារៀនខ្ញុំឈ្មោះសាលារៀន. ...... ។ សង់នៅ ...... ។ មានថ្នាក់រៀន........ ។ នៅមុខសាលារៀនមាន ...... មួយ ខ្ញុំ ...... សាលារៀនខ្ញុំណាស់ពីព្រោះអ្វីគឺនៅទីនេះហើយដែលខ្ញុំមក ....... រាល់ថ្ងៃឲ្យបាន ........ ។

## សេចក្ដីតែងទី ២

## អំពីថ្នាក់រៀនរបស់ខ្ញុំ

សូមគ្រូរៀបចំរឿងតែងនេះ ។

## សេចក្ដីតែងទី ៣

## អំពីខ្លួនមនុស្ស

វិធីហាត់មាត់ទទេ.- ខ្លួនមនុស្សមានប៉ុន្មានចំណែក? គឺអ្វីខ្លះ? ក្បាលជាប់មកដងខ្លួននឹងអ្វី? ដងខ្លួនជាប់ទៅជើងនឹងអ្វី? អវៈយវៈ គឺអ្វីខ្លះ?

វិធីហាត់សរសេរ.– ចូររើសរកពាក្យត្រឹមត្រូវមកដាក់បំពេញ ចន្លោះកន្លែងខាងក្រោមនេះ ៗ

ខ្លួនមនុស្សមាន ......... ចំណែកគឺ......;....., ទីង ......... ..ៗ

អវៈយវៈលើគឺ .. .. .. អវៈយវៈក្រោមគឺ .. .. .. ៗ

### សេចក្ដីតែងទី ៤

### អំពីខ្លួនមនុស្ស

សូមគ្រូរៀបចំរឿងតែងនេះ ៗ

---

## អាទិកាដ្ឋាន

| គព្វន្ត |
|---|

ចំនួនពី ១ ដល់ ១០០

លេខបូក – រាប់ម្ដង ៧, ម្ដង ៨

បង្កើតឡើងឬបន្ថយចុះ

មតិសំខ្យា– ១៩ + ២១ , ១៥ + ២៥

សេចក្ដីសំខាន់: វេលាដែលបង្រៀន នព្វន្តមួយៗ កុំឲ្យបង្រៀនតែលេខទទេ ត្រូវមានវត្ថុផ្សេងៗ ដូចជាចង្កឹះ, ចំរៀកឫស្សី, ដុំគ្រួស, ដងប៉ាកកា, លុយសេន, ដីស ។ល។ ដើម្បីឲ្យសិស្សរៀនរាប់ ហើយឃើញច្បាស់លាស់ទីផ្នែក ៗ

## របៀបបង្រៀន

១)- ការហាត់គិតមាត់ទទេ ឲ្យសិស្សរាប់ចង្កឹះ ឬដុំគ្រួស ពី ១ ដល់ ១០០ បង្កើនម្ដង ៧ ម្ដង ៨ បន្ថយពី ១០០ ម្ដង ៧ ម្ដង ៨ ៗ

២)- ការហាត់បញ្ជាក់មើលចំនួន ចង្អុលចំនួនដែលសរសេរទុក នៅលើក្ដារខៀនឲ្យសិស្សមើល ហើយគ្រូសាកសួរអំពីខ្ទង់រាយ, ខ្ទង់ដប់, ខ្ទង់រយ ៗ

៣)- ការហាត់បញ្ជាក់សរសេរចំនួននៅលើក្ដារធ្នួន

គ្រូសូត្រលេខឲ្យសិស្សសរសេរតាមដូចជាលេខ=

៦, ១២, ២១, ៣, ៤២, ១១, ៣៦, ៦៦, ៧២, ៩១, ៨៥, ៣៧, ។ល។

៤)- ការហាត់សរសេរនៅក្នុងសៀវភៅ.–

៤២ស + ៧ស = សេន

៣៤ស + ៦ស = សេន

២១ស + ៩ស = សេន

៦៨ស + ១៦ស = សេន

៥៣ស + ស = ៧៧ សេន

៣៦ស + ស = ៦៧ សេន

២៩ស + ស = ៧១ សេន

៥)- បំណោទ ១) ក្នុងច្បារមួយ មានដើមស្វាយ៨០ដើមៗ គេដាំថែម ១៥ ទៀត ។ តើដើមស្វាយទាំងអស់មានប៉ុន្មានដើម ។

២) ម្ដាយខ្ញុំគាត់ទិញអាវ ១ ថ្ងៃ ៩៤រ, គាត់លក់ទៅវិញបាន ចំណេញ ៥រ ។ តើម្ដាយខ្ញុំគាត់លក់អាវនោះថ្លៃប៉ុន្មាន ?

៣) ឈ្មួញម្នាក់ទិញពោតម្ដង ២០ បាវ, ម្ដងទៀត ៣៥ បាវ, ម្ដងទៀត ៤៦ បាវ ។ តើឈ្មួញនោះទិញបានពោតទាំងអស់ប៉ុន្មានបាវ ?

ការហាត់គិតលេខដោយមតិសំខ្យា = ដូចជាលេខ:

១៩ + ២១

របៀបទី ១.– គេគិតថា: ២០ បូកនឹង ២១ ត្រូវជា ៤១; ៤១ដក ១ ចេញ នៅសល់ ៤០ ។

សេចក្ដីពន្យល់– ដើម្បីឲ្យស្រួលគិត គេបន្ថែម១ទៅលើ១៩ ឲ្យបានជាលេខដុំ ២០ ឡើង ។ រួចគេបូក ២០ + ២១ ត្រូវជា ៤១; ឯ ៤១ នេះត្រូវដក ១ ចេញ ដែលយើងបន្ថែមទៅលើ១៩នោះ ។

របៀបទី ២– គេដក ១ ពី ២១ រួចយកទៅបូកបន្ថែមលើ ១៩ ត្រូវជា ២០ ។ លេខទាំង២ស្មើគ្នាគឺ ២០ + ២០ ត្រូវជា ៤០ ដូចជា លេខ ១៥ + ២៥

- គេគិតថា ៥ បូកនឹង ៥ ត្រូវជា ១០ ។ ១០ បូកនឹង ២០ ត្រូវជា ៣០, ៣០ បូកនឹង១០ ត្រូវជា ៤០ ។

ឬ ដក ៥ ពី ២៥ ចេញ យកទៅបន្ថែមលើ ១៥ ។ លេខទាំង ២ ស្មើគ្នា គឺ ២០ + ២០ ត្រូវជា ៤០ ។

## រង្វាស់រង្វាល់

### ម៉ែត្រ លីត្រ បួនជ្រុងស្មើ

អាទិត្យដំបូង.– ម៉ែត្រជារង្វាស់ខ្នាតដើម នៃវិធីវាស់ប្រវែង គេប្រើសំ

រាប់វាស់ប្រវែង ទទឹង បណ្ដោយ កំពស់ ទំងន់ជំរៅ វត្ថុទាំងឡាយដូចជាតុ ក្ដារសៀ ក្ដារខៀនបញ្ជរ បន្ទប់រៀន ដីស្រែ ភូមិ ចំការ ។ល។ ម៉ែត្រមានច្រើនយ៉ាង គឺម៉ែត្រឈើបន្ទាត់ ម៉ែត្រឈើបត់ ម៉ែត្រដែក ឬស្ពាន់បត់ ម៉ែត្រសំពត់ ។

ពិតមែនតែម៉ែត្រមានច្រើនដូច្នេះ តែប្រវែងម៉ែត្រទាំងនេះស្មើគ្នាទាំងអស់ជាខ្នាតទៀងណាស់ ហើយបានគេធ្វើឲ្យមានច្រើនបែបយ៉ាងនេះ គឺឲ្យងាយដល់អ្នកប្រើការដូចជាឈ្មួញសំពត់ ប្រើម៉ែត្របន្ទាត់ ជាងធ្វើផ្ទះជាងឈើ ប្រើម៉ែត្របត់ធ្វើទឹងឈើ ឬធ្វើទឹងដែក ជាងដេរខោ-អាវ ប្រើម៉ែត្រសំពត់ ។ សូមរកម៉ែត្រគ្រប់បែបមកបង្ហាញសិស្សឲ្យមើល ឲ្យសង្កេត ឲ្យបានគ្រប់គ្នា ។

ម៉ែត្រ គេសរសេរកាត់ "ម" ដូចជា ១ម ៥ម ៧ម ..... ។

**ការហាត់គិតមាត់ទទេ .—** ម៉ែត្រសំរាប់ធ្វើអ្វី? ម៉ែត្រមានប៉ុន្មានយ៉ាង ម៉ែត្រអ្វីខ្លះ? ម៉ែត្រណាវែងជាងគេ? ហេតុអ្វីបានជាគេធ្វើម៉ែត្រច្រើនយ៉ាងដូច្នេះ? ជាងដេរខោ-អាវប្រើម៉ែត្រអ្វី? ជាងឈើប្រើម៉ែត្រអ្វី?

**ការហាត់វាស់ និង ហាត់ស្មានប្រវែង .—** បង្ហាញបណ្ដោយតុ កំពស់ក្ដារខៀន ជំរៅធុងទឹក ឲ្យសិស្សស្មានប្រវែង រួចនាំសិស្សឲ្យវាស់ឲ្យបានច្រើនគ្នា ។

បំណោទ .- ១) ជាងដេរខោ-អាវម្នាក់ប្រើសំពត់អស់ ២ មុ ក្នុងកាត់ខោមួយ ៗ ក្នុងសំពត់ ១៤ មុ តើកាត់បានខោប៉ុន្មាន ? ។

២) ចិនម្នាក់ទិញសំពត់ ៣៩ មុ ហើយលក់ ៦ មុ ទៅវិញតើចិននោះនៅសល់សំពត់ប៉ុន្មានម៉ែត្រទៀត ? ។

៣) ឈ្មួញម្នាក់ទិញខ្សែលួសមួយ ៧៥ ម៉ែត្រ មួយទៀត ២៥ ម៉ែត្រ ឈ្មួញនោះយកទៅលក់វិញអស់ ៥៣ ម៉ែត្រ តើនៅសល់ខ្សែលួសប៉ុន្មានម៉ែត្រលក់ទៅមុខទៀត ? ។

## អាទិត្យបន្ទាប់ .- អំពីលីត្រ

សូមគេរង្វាល់មកឲ្យសិស្សពិនិត្យ បើគ្មានសូមឲ្យបង្ហាញគំនូរ ឬគូរនៅក្ដារខៀនឲ្យមើល ។

លីត្រជារង្វាល់ ប្រើសំរាប់វាល់វត្ថុរាវ ដូចជាស្រា ប្រេង ខ្លាញ់ ទឹក និងវត្ថុក្រៀមឬគ្រាប់ ដូចជាអង្ករ ស្រូវ សណ្ដែក ល្ង ។ល។

លីត្រមានចំណុះស្មើគ្នាទាំងអស់ ប៉ុន្តែមានរាង ឬបែបខុសគ្នា រង្វាល់លីត្រដែលមានដាក់ស្ដង់នោះមាន ៣ យ៉ាង ។

១) លីត្រធ្វើនឹងដែកស៊ីវិឡាត ឬសំណប៉ាហាំង មានដៃកាន់ពីក្រោយ សំរាប់វាល់ខ្លាញ់ ប្រេង ទឹក ។ល។

២) លីត្រធ្វើនឹងស្ពាន់ស មានដៃយួរសំរាប់វាល់ស្រា ទឹកដោះគោ ទឹកសាអ៊ីវ ។ល។

៣) លីត្រធ្វើនឹងឈើ សំរាប់វាល់វត្ថុក្រៀម ដូចជា ម្សៅ ពោត អង្ករ ស្រូវ ល្ង សណ្តែក ។ មានលីត្រ ១ យ៉ាងទៀត ហៅថាលីត្រដប ។

ឯលីត្រដបនេះគេធ្វើសំរាប់ដាក់ស្រា ដាក់ទឹកថ្នាំ និងវត្ថុឯទៀតរាវ ដូចជាទឹក ។ លីត្រដបនេះ ពុំមែនប្រើសំរាប់វាល់ដូចលីត្រឯទៀតនោះទេ គឺគេធ្វើសំរាប់ដាក់ស្រា ឬថ្នាំឲ្យដឹងចំនួននឹងកំណត់ ។

ហាត់គិតមាត់ទទេ ។ — រង្វាល់ ដែលជាប្រធានមានរូបជាក់-ស្តែងគឺអ្វី ? បើគេចង់ដឹងចំនួនវត្ថុរាវ ដែលគេថ្លឹងពុំបាននោះ គេធ្វើដូចម្តេច ? លីត្រជាអ្វី ? មានប៉ុន្មានយ៉ាង ? លីត្រឈើសំរាប់ប្រើធ្វើអ្វី ?

សូមសួរណែនាំពីបែបលីត្រដែលមានផ្សេងៗ ហើយនឹងប្រយោជន៍នៃលីត្រនីមួយៗ ។

សូមឲ្យសិស្សដឹងជាក់ច្បាស់ថា រង្វាល់ឯណាឈ្មោះថាលីត្រនោះ មានបំណុះស្មើគ្នាទាំងអស់ ។ ប្រាប់សិស្សថា ខ្មែរយើងពុំមានទម្លាប់ប្រើលីត្រទេ សន្មតគ្នាយកចានឬតែងមកប្រើម្ល៉ោះហើយពុំដែលបានទៀងទាត់ដោយចានឬតែងមានតូចមានធំ ។

នាំសិស្សឲ្យមើលរបស់ផ្សេងៗ ដូចជា ទឹក អង្ករ ស្រូវ ពោត សណ្តែក ៗ ប្រាប់សិស្សឲ្យច្បាស់ថា កន្ទ ១ តៅ មាន ១៥ លីត្រ កន្ទ ១ ប៉ោត មាន ១៨ លីត្រ នោះជាទៀងទាត់ ៗ

## ការហាត់សរសេរ និងបំណោទ

២៨ល + ៣១ល =

៦១ល + ១៨ល =

៩៨ល − ៥៨ល =

៨៥ល − ៤៦ល =

១) នៅក្នុងក្រឡមួយមានស្រា ៣១ លីត្រ គេដួសលក់អស់ ២១ លីត្រ ៗ តើនៅសល់ស្រាប៉ុន្មានលីត្រទៀតក្នុងក្រឡនោះ ?

២) ទឹកនៅក្នុងធុងមាន ៦៩ លីត្រ គេប្រើការអស់ ១២ លីត្រ ហើយដងទាក់មកវិញ ២១ លីត្រ ៗ តើនៅក្នុងធុងមានទឹកប៉ុន្មានលីត្រ ?

## ប្អូនប្រុងស្មើ

មេរៀននេះ នៅតែក្នុងវង្វាស់វង្វាល់ដែលមិនមែនបញ្ចូលទៅក្នុងធរណីមាណសាស្ត្រទេ ៗ ក្នុងមេរៀននេះ សូមបង្ហាញ សិស្សឲ្យស្គាល់ប្អូនប្រុងស្មើទឹងមើលគេបរិវេណប៉ុណ្ណោះទេ ៗ

**ការហាត់សំគាល់បួនជ្រុងស្មើ ។ —** គូរបួនជ្រុងស្មើ នៅក្ដារខៀន បង្ហាញប្រវែង ជ្រុងទាំងបួន (ស្មើគ្នាទាំងអស់) ។ ឥដ្ឋពណ៌ក្រាលជាបួនជ្រុងកាត់ក្រដាសជាបួនជ្រុងស្មើ បង្ហាញសិស្ស ។




**ន័យ ។ —** បួនជ្រុងស្មើគឺចតុរង្គ ដែលមានជ្រុងទាំងបួនស្មើគ្នា ។

**ការហាត់រកបរិវេណ ។ —** នាំសិស្សឲ្យសង្កេតគំនូរខាងក្រោមនេះ ៖




បរិវេណ នៃបួនជ្រុងស្មើ គឺប្រវែងជ្រុងមួយ ៗ បួនដង ឬ ៖ ១ សម + ១ សម + ១ សម + ១ សម ឬ ១ សម × ៤ = ៤ សម ។




**ន័យ ។ —** បរិវេណនៃបួនជ្រុងស្មើ គឺប្រវែងជ្រុងស្មើទាំងបួនរួមគ្នា ។

## ការបាត់គិតមាត់ទទេនឹងបាត់សរសេរ–

យ៉ាងដូចម្ដេចដែលហៅថា បួនជ្រុងស្មើ ?

របស់អ្វីខ្លះ ដែលមានរាងជាបួនជ្រុងស្មើ ?

## ការបាត់គិតសរសេរ.–

សូមរកបរិវេណបួនជ្រុងស្មើ ដែលមានជ្រុងនីមួយ ៗ ប្រវែង ១២ ម ? ១៥ ម ? ៣០ ម ? ៥០ ម ,

បំណោទ .– ១) ច្បារដំណាំមួយ មានរាងបួនជ្រុងស្មើ ៗ ជ្រុងមួយ ៗ ប្រវែង ៣៥ ម គេព័ទ្ធខ្សែលួសបន្ទាជុំវិញច្បារនោះ ៣ ជុំ ធ្វើជារបង ៗ

គេប្រើខ្សែលួសអស់ប៉ុន្មានម៉ែត្រ ?

---

បរិច្ឆណាដ្ឋាន



## មេរៀនទី ១ .– សាមញ្ញាក់អំពីចំនួនពី ១ ដល់ ១០០

## របៀបបង្រៀន.-

១- ការហាត់គិតមាត់ទទេ.- ឲ្យសិស្សរាប់របស់បន្ថែម មួយ ៗ ពីរ ៗ បី ៗ បួន ៗ ពី ១ ដល់ ១០០ ហើយរាប់បន្ថយមកវិញ

២- បញ្ជាក់លើការរាប់ចំនួនៈ មានដប់ប៉ុន្មានដង និងរាយប៉ុន្មាន ក្នុងចំនួន ១៧ - ២៥ - ៣៩ - ៤៣ - ៥៨ - ៦១ - ៧៤ - ៨៦ - ៩២.... ។

៣- បញ្ជាក់លើការរៀនអានចំនួន.-

៤ បញ្ជាក់លើការរៀនសរសេរចំនួន.-

៥- ការហាត់សរសេរនៅក្នុងសៀវភៅ.-

ក - ចូរគិតចំនួនខាងក្រោមនេះ

១៤ស + ៥ស = ។ ២៤ស + ៧ស = ។

២៣ស + ៤ស = ។ ៤៩ស + ៣ស = ។

៥៧ស + ៣ស = ។ ២១ស + ៤ស = ។

៦៩ស + ៤ស = ។ ៣២ស + ៣ស = ។

៦- បំណោទ.- ខ្ញុំទិញសំពត់ ១ម ថ្លៃ ១៥ រៀល ទិញស្បែកជើង ១ សំរាប់ថ្លៃ ៤៧ រៀល ។ ខ្ញុំត្រូវចាយអស់ប្រាក់...រៀល ។ បើខ្ញុំឲ្យក្រដាសប្រាក់ ១០០ រៀលទៅគេ ៗ ត្រូវអាប់ .... រៀលមកឲ្យខ្ញុំវិញ ។

## មេរៀនទី ២.– ចំនួនដល់ ១០០ – លេខបូកឥតត្រាទុក

### របៀបបង្រៀន.–

១– ការហាត់គិតមាត់ទទេ.– រាប់របស់បន្ថែម ពីរ ៗ បី ៗ បួន ៗ ពី ១ ដល់ ១០០ ។

២– ពន្យល់របៀបធ្វើលេខបូក

| | |
|---|---|
| + ២៣ស | + ១៩ស |
| ៣៤ស | ៤៣ស |
| ៥៧ស | ៦២ស |

៣– ការហាត់បញ្ចូលនៅលើក្ដារខៀនដីលើក្ដារឆ្នួន

១៣ស + ២៥ស = .. ។ ៤៣ស + ២៦ស = .. ។

២៥ស + ៣៦ស = .. ។ ៤៧ស + ៣៥ស = .. ។

៤– ការហាត់សរសេរនៅក្នុងសៀវភៅ

| | | | |
|---|---|---|---|
| + ១៤ស | + ២៥ស | + ៣៧ស | + ៤៦ស |
| ២៣ស | ៣២ស | ១៥ស | ៣៥ស |

បំណោទ.– ម្ដាយខ្ញុំទៅផ្សារគាត់ទិញត្រីទឹកសាច់ជ្រូកអស់ ២៧ រៀល ទិញបន្លែទឹកសាច់គោអស់ ២៥ រៀល តើគាត់ចាយអស់ប្រាក់ប៉ុន្មានទាំងអស់ ។

## មេរៀនទី ៣.– ចំនួនដល់ ១០០ - លេខសងឥតត្រាទុកនឹងមានត្រាទុក

សូមធ្វើតាមរបៀបបង្រៀនលេខបួក

មេរៀនទី ៤.- ចំនួនពី ១០០ ដល់ ១១៩

ការរៀនរាប់ - រៀនអាន - រៀនសរសេរចំនួន ។

របស់សំរាប់បង្រៀន.- បំពង់សំរាប់ខ្ទង់រាយ ខ្ទង់ដប់ ខ្ទង់រយ នឹងបន្ទះមីពណ៌សំរាប់ខ្ទង់តាំងពី .




របៀបបង្រៀន.- ១- គ្រូដាក់បន្ទះទៅក្នុងបំពង់ដូចរបៀប ខាងលើនេះ

២- សួរសាកអំពីចំនួនខាងលើនេះហើយពន្យល់អំពីខ្ទង់

៣- គ្រូសរសេរចំនួននោះនៅលើក្តារខៀន ហើយពន្យល់របៀប សរសេរចំនួននោះ

៤- ឲ្យសិស្សដាក់បន្ទះក្នុងបំពង់ឲ្យបានជាចំនួនមួយដែលគ្រូថា

៥ ឲ្យសិស្សសរសេរចំនួននោះ

៦- សារបញ្ជាក់ឡើងវិញ

៧- ការហាត់គិតមាត់ទទេ

៨- ការហាត់សរសេរនៅក្នុងសៀវភៅ

មេរៀនទី ៥.- ចំនួនដល់ ១១៩ - លេខបូកឥតត្រាទុកនិងមានត្រាទុក

មេរៀនទី ៦.- ចំនួនពី ១២០ ដល់ ១៣៩.

ការរៀនរាប់ រៀនមើល រៀនសរសេរចំនួន

មេរៀនទី ៧.- ចំនួនដល់ ១៣៩ - លេខសងឥតត្រាទុកនិងមានត្រាទុក

សូមមើលតាមរបៀបខាងលើ ហើយបង្រៀនសិស្សឲ្យចេះដល់ចំនួន ២០០ ហើយឲ្យចេះធ្វើលេខបូកនិងលេខសងឥតត្រាទុកនិងមានត្រាទុក ៗ

## រង្វាស់រង្វាល់

កន្លែងនេះគ្រូបង្រៀនសិស្សឲ្យស្គាល់ម៉ែត្រ លីត្រ ក្លូទម្ងន់ឲ្យច្បាស់ ហើយឲ្យសិស្សស្គាល់រង្វាស់-រង្វាល់ទាំងនោះគ្រប់បែប ចេះប្រើប្រាស់ឲ្យស្ទាត់ ៗ

ឯរបៀបបង្រៀន មានរបៀបតែងជាគំរូនៅថ្នាក់កុមារដ្ឋានសព្វគ្រប់គ្រាប់ហើយ ។

---

កុមារដ្ឋាន

## គណិត

មេរៀនទី ១.– ចំនួនពី ១ ដល់ ៥

ការរៀនរាប់ - រៀនមើល - រៀនសរសេរចំនួន ។

របស់សំរាប់បង្រៀន.– បង្គើះឬគ្រាប់គ្រួសឬលុយសេន ។

របៀបបង្រៀន.–

១ – ការរៀនរាប់ចំនួន. – គ្រូលើកបង្គើះ ១ - គ្រួស ១ គ្រាប់ ឬលុយ ១ សេនបង្ហាញសិស្ស ហើយសួរឬប្រាប់សិស្សថា "នេះបង្គើះ ១ - គ្រួស ១ គ្រាប់ឬលុយ ១ សេន ។ ឲ្យសិស្សថាតាម ។ ឲ្យសិស្សលើករបស់ "មួយ" បង្ហាញ ដូចជាសៀវភៅ ១. ខ្មៅដៃ ១

២ - ការរៀនមើលចំនួន.– គ្រូគូសចំនួនបង្គើះ ១ ឬលុយ ១ សេននៅលើក្តារខៀន ហើយសរសេរលេខមួយនៅក្រោមគំនូសនោះ

នាំសិស្សអានលេខ ១ នោះ

៣– ការរៀនសរសេរចំនួន.– គ្រូពន្យល់របៀបសរសេរចំនួន ១ ដោយសរសេរនៅលើក្ដារខៀនឲ្យសិស្សមើល ហើយពន្យល់របៀបសរសេរបណ្ដើរ ៗ

នាំសិស្សរៀនសរសេរចំនួននោះដោយដៃទទេបង្ហើរដោយខ្យល់ រួចសរសេរនៅលើក្ដារខៀនរួចនៅលើក្ដារឆ្នួន ៗ

កាលណាសិស្សស្គាល់ចំនួន ១ ចេះអាន ចេះសរសេរចំនួន ១ ច្បាស់ហើយ ចាប់បង្រៀនចំនួន ២.៣.៤-៥ តទៅទៀតតាមរបៀបខាងលើនេះ ៗ

## ការហាត់បញ្ជាក់ឡើងវិញ.–

១– បញ្ជាក់អំពីការរៀនរាប់ចំនួន.- គ្រូលើករបស់ ៣-៥-២-១- បង្ហាញសិស្សឲ្យរាថាចំនួន ៗ

គ្រូថាចំនួនរបស់ឲ្យសិស្សលើកបង្ហាញ

២– បញ្ជាក់អំពីការរៀនមើលចំនួន.– គ្រូចង្អុលចំនួនដែលសរសេរនៅលើក្ដារខៀនឲ្យសិស្សថា រួចគ្រូថាចំនួនឲ្យសិស្សចង្អុល ៗ

៣– ការបញ្ជាក់អំពីសរសេរចំនួន.– គ្រូថាចំនួនឲ្យសិស្សសរសេរនៅលើក្ដារឆ្នួន ៗ

ការបំណាំ.- ដើម្បីឲ្យសិស្សសរសេរលេខឲ្យបានល្អសុំកុំអធ្យាស្រ័យឲ្យសោះ ព្រោះកាលណាបើសរសេរលេខបានល្អវានឹងភ្ជាប់សរសេរល្អទៅថ្ងៃក្រោយ ។

## មេរៀនទី ២.- ចំនួនពី ៦ ដល់ ៩

ការរៀនកប់-រៀនមើល-រៀនសរសេរចំនួន ។

សុំមើលតាមរបៀបខាងលើ ប៉ុន្តែមុននឹងចាប់បង្រៀនត្រូវរំញាក់អំពីចំនួនដែលបានរៀនពីថ្ងៃមុនសិន ។

## មេរៀនទី ៣.- ចំនួនដល់ ៩.- រៀនធ្វើលេខបូក ។

របស់សំរាប់បង្រៀន.- បន្ទះឬគ្រាប់គ្រួសឬលុយសេន ។

របៀបបង្រៀន.-

១ ការហាត់គិតមាត់ទទេ.- នាំសិស្សរៀនកប់បន្ទះ គ្រាប់គ្រួសឬលុយសេន បន្ថែមមួយ ៗ ពី ៗ បី ៗ ពី ១ ដល់ ៩ ។

២- ពន្យល់របៀបធ្វើលេខបូក.- ឲ្យសិស្សម្នាក់កាន់បន្ទះ ៤ ម្នាក់ទៀតកាន់បន្ទះ ៣ តើសិស្សទាំងពីរនាក់មានបន្ទះប៉ុន្មាន ។

គ្រូតាំងលេខបូកនេះហើយធ្វើទៅលើក្ដារខៀនជាមួយសិស្សទាំងអស់ ។

```
  ៥ប
+ ៣ប
-----
  ៨ប
```

៣= ការហាត់បញ្ជាក់នៅលើក្ដារខៀន ៖ ៤ស + ៣ស =... ។ ៧ស + ២ស =... ។ ៥ស + ៤ស -... ។

៤- ការហាត់បញ្ជាក់នៅលើក្ដារឆ្នួន ៖ ៦ស + ២ស -... ។ ៤ស + ៣ស -... ។ ៥ស + ៣ស -... ។ល។

មេរៀនទី ៤·- ចំនួនដល់ ៩ - លេខសូន្យ

សុំមើលតាមរបៀបបង្រៀនធ្វើលេខបូកខាងលើនេះ ។

មេរៀនទី ៥· ចំនួនពី ១០ ដល់ ១៩

របស់សំរាប់បង្រៀនៈ បន្ទះកាយ - បន្ទះដប់បន្ទាត់ ប្លុយ សេនទីម៍ ប្រាក់កាក់ ១០ សេន ។

របៀបបង្រៀនៈ-

១ - សួរសាកបញ្ជាក់អំពីចំនួនដែលបានរៀនមកហើយ(ពី១ដល់៩)

២- រៀនចំនួន ១០ - គ្រូលើកបន្ទះ គ្រាប់គ្រួសប្លុយ ៩ បង្ហាញ

សិស្សឲ្យរាប់ជាចំនួន  រួចបន្ថែមចំនួន ១ ទៅលើចំនួននោះ  ត្រូវជាប៉ុន្មាន (ត្រូវជា១០)

៣- គ្រូសរសេរចំនួន ១០ នៅលើក្ដារខៀនហើយ  ពន្យល់ដោយសួរសាកអំពីរបៀបសរសេរចំនួន ១០ នោះ

៤- គ្រូឲ្យសិស្សអានចំនួនដែលសរសេរនៅលើក្ដារខៀន

៥- ឲ្យសិស្សសរសេរចំនួន ១០ នៅលើក្ដារឆ្នួន

កាលណាសិស្សស្គាល់-ចេះអានចេះសរសេរចំនួន១០ច្បាស់ហើយ ទើបលោកគ្រូចាប់បង្រៀនចំនួន ១១ តទៅទៀត ធ្វើតាមរបៀបនេះរហូតដល់ ១៩ ។ ត្រូវពន្យល់ដោយសួរសាកអំពីខ្ទង់នៃលេខដូចជាចំនួន ១៣ មានលេខ ១ និងលេខ ៣ លេខ១នៅខ្ទង់១០ លេខ៣នៅខ្ទង់រាយ

៦- សាបញ្ញាក់អំពីចំនួនដែលបានរៀននោះដូចរបៀបមុន ៗ

មេរៀនទី ៦.- ចំនួនដល់ ១៩ .លេខបូក

មេរៀនទី ៧.- ចំនួនដល់ ១៩ -លេខសង

សូមមើលតាមរបៀបមុន ៗ

## រង្វាស់រង្វាល់

តាមកំណត់ថែកវិជ្ជា  ក្នុងថ្ងៃនេះត្រូវបង្រៀនអំពីរង្វាស់ម៉ែត្រ ឲ្យសិស្សស្គាល់ប្រវែង១ម៉ែត្រឲ្យច្បាស់ ឲ្យចេះស្មាន ឲ្យចេះវាស់ ឲ្យស្គាល់ម៉ែត្រគ្រប់បែបឲ្យចេះប្រើប្រាស់ ។

មេរៀនទី ១.- អំពីរង្វាស់ម៉ែត្រ

របស់សំរាប់បង្រៀន.- ម៉ែត្របត់ឬម៉ែត្របន្ទាត់

របៀបបង្រៀន.-

១- គ្រូលើករង្វាស់ម៉ែត្របង្ហាញសិស្ស  ហើយសួរឬប្រាប់សិស្សថានេះរង្វាស់ម៉ែត្រ–មានប្រវែង១ម៉ែត្រ

២- នាំសិស្សពិនិត្យមើលប្រវែង១ម៉ែត្រដោយបង្ហាញ  ហើយគូសបន្ទាត់ប្រវែង១ម៉ែត្រនៅលើក្តារខៀន  ឲ្យសិស្សស្គាល់ប្រវែង១ម៉ែត្រឲ្យច្បាស់ ។

៣- ការហាត់ស្មាន-ឲ្យសិស្សគូសបន្ទាត់មានប្រវែង១ម៉ែត្រនៅលើក្តារខៀនហើយវាស់បញ្ជាក់  ឬឲ្យស្មានបណ្តោយរបស់អ្វីមួយដែលមានប្រវែង ១ម ២ម ៣ម

៤- ការហាត់គិត.– ខ្សែលួស១កំណាត់ប្រវែង ៥ម គេយកទៅតនឹងខ្សែលួស១កំណាត់ទៀតប្រវែង ៣ម ហើយគេកាត់យក ៧ម ចេញតើត្រូវនៅសល់ប៉ុន្មានម៉ែត្រ ។

## មេរៀនទី ២.– អំពីម៉ែត្រ (ត)

បង្ហិកសិស្សឲ្យចេះស្ទាន ចេះប្រើប្រាស់វង្វាស់ម៉ែត្រឲ្យស្ទាត់តាមរបៀបខាងលើនេះ ។

## មេរៀនទី ៣·– អំពីម៉ែត្រគ្រប់បែប

របស់សំរាប់បង្រៀន·– ម៉ែត្របត់ ម៉ែត្របន្ទាត់ ម៉ែត្រសំពត់ សំពត់ឬខ្សែ

របៀបបង្រៀន.–

១– សួរសាកបញ្ជាក់អំពីវង្វាស់ម៉ែត្រ

២– ពិនិត្យវង្វាស់ម៉ែត្រគ្រប់បែបឲ្យឃើញថា ម៉ែត្រទាំង៣បែបនេះ រូបរាងខុសគ្នាពិត ប៉ុន្តែប្រវែងគ្នាទាំងអស់

៣– ការប្រើប្រាស់ម៉ែត្រគ្រប់បែប– នាំសិស្សធ្វើជាងឈើជាអ្នកប្រើម៉ែត្របត់ ធ្វើអ្នកលក់សំពត់ជាអ្នកប្រើម៉ែត្របន្ទាត់ ធ្វើជាងកាត់ខោអាវជាអ្នកប្រើម៉ែត្រសំពត់

៤– ការហាត់គិតមាត់ទទេ ។

សូមធ្វើតាមរបៀបមុន ។

# វិត្តស្វាធ្យាយន៍

## សំរាប់អាទិកដ្ឋាន

### អាទិត្យទី ១– ខ្លួនមនុស្ស

សម្ភារ: គ្រូត្រូវយកផ្ទាំងគំនូររូបមនុស្សមកពន្យល់សិស្ស ឬឲ្យសិស្សម្នាក់ដោះអាវ-ខោ ស្លៀកតែខោទ្រនាប់ហើយមកឈរនៅមុខគុ សិស្ស ៗ គ្រូចោទសួរហើយនាំសិស្សពិនិត្យមើលឲ្យជាក់ ៗ ខ្លួនមនុស្សយើងមានប៉ុន្មានចំណែក? (មានបីចំណែកគឺ: ក្បាល, ដងខ្លួន និង អវយវៈលើក្រោម) ក្បាលមានឆ្អឹងច្រើនផ្គុំគ្នា ហើយគេចែកជាពីរចំណែកផ្សេងពីគ្នា គឺលលាដ៍ ហើយនិងមុខ ៗ លលាដ៍ក្បាលមានឆ្អឹងសំប៉ែត ឬកោងបន្សំជាប់គ្នាមានសណ្ឋានដូចជាប្រអប់មូលពងក្រពើហើយមានខួរនៅក្នុង ៗ ឯឆ្អឹងមុខក៏បន្សំគ្នាដែរ ហើយភ្ជាប់សាច់មុខផង ប៉ុន្តែមានរន្ធច្រើន ឯរន្ធពីខាងលើហៅថាភ្នែក កណ្តាលហៅថាច្រមុះ ហើយនៅខាងក្រោមមានឆ្អឹងពីរ កោងអមប្រហោងមាត់គឺថ្គាម ហើយមានធ្មេញនៅនោះ ៗ

ដូច្នេះឆ្អឹងក្បាលសុទ្ធតែបន្សំជាប់គ្នាទាំងអស់ ហើយកំរើកមិនបាន

ទេ ។ មានតែថ្គាមក្រោមមួយដែលអាចកំរើកបាន ។

ដងខ្លួនយើងចែកជាប៉ុន្មានចំណែក ? ចំណែកអ្វីខ្លះ ? (ទ្រូងហើយនឹងពោះ) ។ អវយវៈមានប៉ុន្មាន? អវយវៈលើភ្ជាប់ទៅនឹងដងខ្លួនកន្លែងណា ? (ត្រង់សន្លាក់ស្មា) ។ ដៃយើងបត់បានកន្លែងណាខ្លះ? (សន្លាក់ស្មា, កដៃ, ម្រាមដៃ) បើប្រសិនណាជាគ្មានសន្លាក់អស់ទាំងនេះទេ ដៃយើងពុំអាចនឹងបត់ចុះឡើងបានឡើយ ។ អវយវៈក្រោមភ្ជាប់នឹងដងខ្លួនកន្លែងត្រង់ណា? អវយវៈក្រោមមានប៉ុន្មានចំណែក? សន្លាក់មានប៉ុន្មាន?

សេចក្ដីសង្ខេប ខ្លួនមនុស្ស

ខ្លួនមនុស្សយើងមានបីចំណែកគឺក្បាល-ដងខ្លួននឹងអវយវៈ ។ កភ្ជាប់ក្បាលទៅនឹងដងខ្លួន ។ នៅក្រោយដងខ្លួនមានឆ្អឹងខ្នង ។ ដងខ្លួនមានពីរចំណែក ៖ ខាងលើគឺទ្រូង ខាងក្រោមគឺពោះ ។ មានអវយវៈបួនភ្ជាប់នឹងដងខ្លួន ៖ ខាងលើពីរខាងក្រោមពីរ ។ ខ្លួនមនុស្សយើងមានសន្លាក់ជាច្រើនប្រយោជន៍ឲ្យបត់ចុះឡើង ។

## មេរៀនលេខ ២ អដ្ឋិសង្ខលិកៈ

ប្រដាប់សម្រាប់បង្រៀន គ្រូត្រូវរកឆ្អឹងសត្វផ្សេងៗ ដូចជាឆ្អឹង

មាន់, ឆ្អឹងទន្សាយ, ឆ្អឹងដែលមានខួរនៅក្នុង ។

ទិដ្ឋភាពនៃឆ្អឹង ឆ្អឹងមានព័ណ៌សព្រៀងៗ ។

បើយើងសង្កេតមើលឆ្អឹងភ្លៅមាន់ យើងនឹងឃើញថាឆ្អឹងនោះមានពងទ្រវែងហើយស្ដួចមានត្រមោងនៅចុងសងខាង៖

ឆ្អឹងណាដែលវែង ៗ មានជាតិទន់នៅខាងក្នុង ។ ជាតិទន់នេះហើយដែលគេហៅថាខួរក្នុងឆ្អឹង ។ ឆ្អឹងកពងតូចមានទំហំទទឹងនឹងបណ្ដោយស្មើគ្នា, ឆ្អឹងនេះគឺជាឆ្អឹងខ្លី ៗ ។ ឆ្អឹងក្បាលពងស្ដើង, គឺជាឆ្អឹងសំប៉ែត ។ ក្នុងខ្លួនមនុស្សយើងមានឆ្អឹងវែង, ឆ្អឹងខ្លីនិងឆ្អឹងសំប៉ែត។ ឆ្អឹងវែងដូចជាឆ្អឹងដៃ, ឆ្អឹងខ្លីដូចជាឆ្អឹងកដៃ; ឆ្អឹងសំប៉ែតដូចជាឆ្អឹងលលាដ៍ក្បាល ។

ឆ្អឹងរឹង យើងមិនអាចកាច់ឆ្អឹងមាន់ឬឆ្អឹងទន្សាយបាក់ទេ៖ ឆ្អឹងគោដែលធំ ៗ ក៏យើងមិនងាយដំបែកខ្ទេចខ្ទីនឹងញញួរបានដោយងាយដែរ ដូច្នេះយើងឃើញថាឆ្អឹងរឹងមែន ។

ហេតុអ្វីបានជាឆ្អឹងរឹងដូច្នេះ? បើយើងយកឆ្អឹងមួយទៅដុត នោះយើងនឹងឃើញថាឆ្អឹងមិនឆេះរលាយទាំងអស់ទេ ៣-៤ នាទីក្រោយមក បើយើងទាញឆ្អឹងចេញពីភ្លើងមក យើងនឹងឃើញផ្នែកឆ្អឹងដែលនៅសល់មានភាពដូចថ្មព័ណ៌សហើយស្រាល គឺជាតិថ្មកំបោរនេះហើយដែលជា

ហេតុនាំឲ្យឆ្អឹងវែង ។

សេចក្តីសង្ខេប ឆ្អឹងមនុស្សយើងមានរាងវែង, ខ្លីឬសំប៉ែត ។ ឆ្អឹងមនុស្សចាស់រឹងពីព្រោះមានជាតិថ្មកំបោរ ។ ឯចំណែកឆ្អឹងកូនក្មេងទន់ហើយអាចនឹងផ្លាស់រាងបានដោយងាយ ។ ប្រជុំឆ្អឹងទាំងអស់ហៅថា អដ្ឋិសង្ខលិកៈ ។

ឆ្អឹងដែលសំខាន់ជាងគេក្នុងខ្លួនយើងគឺឆ្អឹងក្បាល, បន្ទាប់មកទៀតឆ្អឹងខ្នង, ឆ្អឹងជំនីរ, ឆ្អឹងដៃ, ឆ្អឹងជើង ។

មានឆ្អឹងច្រើនដែលមានសន្លាក់ជាប់គ្នា៖ ដូចជាសន្លាក់ស្មា, សន្លាក់កែងដៃ, សន្លាក់កដៃ ។

អាទិត្យទី២— ក្នុងអាទិត្យនេះសុំឲ្យគ្រូពន្យល់ពីការសំខាន់ៗក្នុងការទ្រទ្រង់ជីវិតយើងគឺ ការរំលាយអាហារ, ការដកដង្ហើម, ការឈាមរត់ក្នុងខ្លួននឹងការបញ្ចេញវត្ថុមិនស្អាតមកក្រៅ (ញើស-លាមកទឹកមូត្រ ។

មើលសៀវភៅវត្ថុស្វាធ្យាយ ទំព័រ ១២ ទៅដល់ទំព័រទី ១៦ ។

អំពីសត្វ.— សុំមើលទស្សនាវដ្តី ខែតុលាឆ្នាំសិក្សា ១៩៥១-៥២ ត្រង់ទំព័រទី ៨១-៨២-៨៣-៨៤-នឹង ៨៥ ។

# វិធីបង្ការរោគ

## សម្រាប់អាធិកដ្ឋាន

### អាទិត្យទី ១– មេរៀនទី ១– ការសំអាតខ្លួន

យើងមិនដកដង្ហើមតែតាមសួតទេ យើងដកដង្ហើមតាមគ្រប់រន្ធញើស ។ ប្រយោជន៍ឲ្យសុខសប្បាយខ្លួនត្រូវថែស្បែកឲ្យស្អាត ត្រូវដុសលាងខ្លួនឲ្យសព្វទាំងអស់ដោយហោចណាស់ពីរដងមួយអាទិត្យ ។ បើសំអាតខ្លួនបានរាល់ថ្ងៃក៏រឹតតែប្រសើរណាស់ទៅទៀត ។ បើយើងសំអាតខ្លួននឹងទឹកទទេមិនទាន់គ្រប់គ្រាន់ទេ ត្រូវប្រើនឹងសាប៊ូផងដើម្បីឲ្យស្អាតមែនទែន ។

ជនណាដែលស្អាត ជននោះពុំសូវមានជម្ងឺបៀតបៀនឡើយ ។

ម្យ៉ាងទៀតត្រូវដុសលាងដៃនឹងសាប៊ូឲ្យរឿយៗ ។ វេលាយើងមុនបរិភោគអាហារ ។ យើងត្រូវដឹងថាដៃនេះហើយដែលតែងតែចាប់កាន់វត្ថុផ្សេងៗមិនស្អាត ។ ក្រចកត្រូវកាត់ឲ្យខ្លី ដើម្បីជៀសវាងការស្មោកគ្រោក ។

### មេរៀនទី ២.– ការសំអាតសំលៀកបំពាក់

មិនគ្រាន់តែសំអាតខ្លួននឹងដៃប៉ុណ្ណោះទេ យើងត្រូវសំអាតសំលៀកបំពាក់ផង ។ ញើសនាំឲ្យធុំក្លិនអាក្រក់ដល់សំពត់អាវណាដែលប៉ះពាល់ផ្ទាល់នឹងស្បែក ត្រូវលាងហើយដុសសាប៊ូសំពត់អាវឲ្យស្អាត ទើបយកមកប្រើប្រាស់ផ្ទាល់ខ្លួន ប្រយោជន៍កុំឲ្យធុំក្លិនអាក្រក់ ។ លាងតែទឹកត្រដាក់មិនបានបរិបូណ៌ទេ ។ ត្រូវស្ងោរលាងសំពត់អាវម្ដង ១ ផង ស្ងោលាង សំពត់អាវត្រូវដាក់សាប៊ូផងប្រយោជន៍ឲ្យបានស្អាតល្អមែនទែន បើគ្មានសាប៊ូគេយកក្បុះមកលាយនឹងទឹកក៏បានដែរ ត្រូវដាក់ក្បុងចំនួន ១ ភាគក្នុងទឹក ១ ផើងចំនួន ៤ ភាគរួចគេកូរិតបញ្ចូលគ្នា ទុកទឹកនោះឲ្យរងថ្លាហើយច្រោះផ្ទេទឹកនោះដាក់ទៅក្នុងផើង ១ ទៀតទើបគេយកទឹកថ្លានោះទៅលាងសំពត់អាវ ។

## អាទិត្យទី ២.– មេរៀនទី១.– ត្រូវស្លៀកពាក់ដូចម្ដេច

សំលៀកបំពាក់ដែលស្រួល គឺសំលៀកបំពាក់មិនចង្អៀត ។ ប្រយោជន៍មិនឲ្យចង្អៀតនេះ ពីព្រោះមិនឲ្យរឹតរួតសរសៃ សាច់ដុំទាំងពួង ដែលជាផ្លូវចង្អូរឈាមនឹងជាទីរំលាយអាហារ ។

ត្រូវថែរក្សាសំលៀកបំពាក់ដូចម្ដេច ។

សំលៀកបំពាក់ក្នុងក្ដី, ក្រៅក្ដី ត្រូវតែស្អាតជាដរាប ត្រូវផ្លាស់ប្ដូរឲ្យ

រឿយ ៗ មិនត្រូវពាក់អាវយឺតឬអាវទ្រនាប់ណាមួយឲ្យនៅយូរលើខ្លួន ដើម្បីកុំឲ្យសត្វមេរោគកើតឡើងបាន ។

មេរៀនទី២.— វិធីបង្ការរោគចំពោះផ្ទះ

នៅទីក្រុងត្រូវរើសកន្លែងសង់ផ្ទះតាមវិថីធំ ៗ នៅស្រុកស្រែត្រូវរើសកន្លែងសង់ផ្ទះនៅទីណាដែលទួលឆ្ងាយពីថ្លុកត្រពាំងឬផ្លូវទឹកផង ។ គួរសង់ផ្ទះឲ្យបានបែរមុខទៅខាងត្បូង ។ ដើមឈើទាំងឡាយធ្វើឲ្យអាកាសបរិសុទ្ធតែកុំឲ្យដាំជិតផ្ទះពេក ដើម្បីទុកឲ្យពន្លឺព្រះអាទិត្យនិងអាកាសចូលក្នុងផ្ទះ ។ ត្រូវសង់ក្រោលគោ - ក្របី - សេះ - ទ្រុងជ្រូក - មាន់ - ទា និងបង្គន់ឲ្យឆ្ងាយពីផ្ទះ ។ រាល់ព្រឹកត្រូវបើកទ្វារបង្អួចទាំងអស់ត្រូវបោសក្តារក្រាលថ្នម ៗ កុំឲ្យធូលីហុយឡើងត្រូវជូតគ្រឿងតុតាំងដោយសំពត់សើម ត្រូវរើពូក - ខ្នើយ - ភួយកន្ទេល - មុងហាលថ្ងៃឲ្យបានញយ ៗ ។ ត្រូវបោសទីភូមិឲ្យបានស្អាតជានិច្ចហើយត្រូវដុតសំរាមចោល ។

សុភាសិត.— កន្លែងណាដែលមានពន្លឺព្រះអាទិត្យចូលកន្លែងនោះពុំសូវមានមេរោគទេ ។

ការថែរក្សាធ្មេញ.— សុំមើលក្នុងទស្សនាវដ្តីឆ្នាំ ១៩៥១-៥២ ខែ-តុលាត្រង់ទំព័រទី ៨៧

ការថែរក្សាសក៏·— សុំមើលទំព័រដដែល

---

បរិវច្ឆណាដ្ឋាន

## វិត្តស្វាធ្យាយន៍

### អាទិត្យទី ១.— អំពីខ្លួនមនុស្ស

១— គ្រូត្រូវយកផ្ទាំងគំនូររូបមនុស្សមកបង្ហាញសិស្សឲ្យស្គាល់ចំណែកខ្លួនមនុស្ស រួចហៅសិស្សម្នាក់មកឈរពីមុខគុសិស្ស ហើយឲ្យដោះអាវចេញហៅសិស្សឯទៀតៗឲ្យពិនិត្យ មើលចំណែករូបកាយយើង ហើយចោទសួរបណ្ដើរ តាមរបៀបដូចមាននៅក្នុងសៀវភៅ វិត្តស្វា-ធ្យាយន៍បរិវច្ឆណដ្ឋានទំព័រទី ៣ និងទី ៤ មានទាំងពាក្យសួរ និងមេរៀនសង្ខេបសំរាប់ឲ្យសិស្សរៀនស្រាប់ហើយ ។

២— អដ្ឋិសន្ធិលិក: ក្បាលដងខ្លួននិងអវយវៈ: បើគ្មានផ្ទាំងគំនូរទេ ត្រូវនាំសិស្សឲ្យមើលគំនូរក្នុងសៀវភៅ រួចឲ្យស្ទាបបង្ហាញលើខ្លួនសិស្សដែលដោះអាវឈរពីមុខគេនោះ ហើយប្រាប់ឈ្មោះឆ្អឹង · ទ្រង់ទ្រាយនិងទំហំឆ្អឹងហើយនិងប្រយោជន៍ឆ្អឹង ហេតុដូចម្ដេចបានជាមានឆ្អឹង

ខ្លះមូល ឆ្អឹងខ្លះសំប៉ែត ឆ្អឹងខ្លះវែង ឆ្អឹងខ្លះខ្លី ?

សុំមើលសេចក្ដីនេះនៅក្នុងសៀវភៅដែលទំព័រទី ៥ និង ៦ ។

## អាទិត្យទី ២– អំពីឆ្អឹងសន្លាក់ឬគណ្ឋិកៈ

សុំមើលក្នុងសៀវភៅដែលទំព័រទី ៨ និង ៩ ។

## អំពីសាច់ដុំ

សុំមើលសៀវភៅដែលទំព័រទី ១០ ។

## វត្ថុស្វាធ្យាយន៍

## អាទិត្យទី ១– អំពីការរំលាយអាហារ

សុំគ្រូគូររូបគ្រឿងប្រដាប់សំរាប់រំលាយអាហារពន្យល់ ហើយបង្ហាញសិស្សឲ្យស្គាល់កន្លែងមាត់បំពង់អាហារ ក្រពះ ពោះវៀន ។

ចោទសួរសិស្សឲ្យឆ្លើយរកការរំលាយអាហារដែលយើងខានមិនបាននោះគឺអ្វីខ្លះ អាហារដែលយើងបរិភោគទៅ បើមិនរលាយល្អទៅ យើងមានជីវិតឬទេ? និងបរិភោគយើងត្រូវការអ្វីខ្លះ? ។

សេចក្ដីសង្ខេប– យើងត្រូវបរិភោគប្រយោជន៍ឲ្យរស់ជីវិត ការដែលបរិភោគអាហារហើយរំលាយអាហារឲ្យទៅជាវត្ថុរាវជ្រាបទៅក្នុង

ឈាមបាននោះហៅថាការរំលាយអាហារ ។

កាលណាយើងបរិភោគ យើងទំពារអាហារដ៏មានទឹកមាត់ផ្សើម អាហារ ធ្លាក់ពីមាត់ទៅបំពង់កទៅក្រពះទៅពោះវៀន នៅក្នុងពោះវៀនអាហារដែលរលាយស្រេចហើយនោះក៏បែកជាពីរចំណែកជាដើម ចំណែកមួយត្រូវនៅក្នុងខ្លួន ចំណែកមួយទៀតត្រូវបញ្ចេញចោលទៅក្រៅ ។

## អាទិត្យទី ២ ការដកដង្ហើម

សុំមើលហើយបង្រៀនតាមសៀវភៅវត្ថុស្វាធ្យាយន៍សំរាប់បរិវុឌ្ឍណ-ដ្ឋានទំព័រទី ១៤

## អាទិត្យទី ៣ អំពីវិញ្ញាណ ៥

វិញ្ញាណប្រាំគឺ កាយវិញ្ញាណ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ជីវ្ហាវិញ្ញាណ នឹងឃានវិញ្ញាណ ។

សុំមើលសៀវភៅដដែលទំព័រ ២០-២១-២២-២៣-២៤-២៥ ។

## អាទិត្យទី ៤ ច្បាប់ដើរនៅផ្លូវ

សុំគ្រូមើលមេរៀនក្នុងសៀវភៅដដែលទំព័រលេខ ១០៤ ។

# វិធីបង្ការរោគ

## អាទិត្យទី ១ វិធីហាត់ប្រាណ

ឲ្យសិស្សពិនិត្យមើលរូបរាងកាយអ្នកស្រែចំការនឹងអ្នកធ្វើការរោងគារ តើខុសគ្នាយ៉ាងណា ? ដោយសារអ្វី ? បើដូច្នេះត្រូវធ្វើដូចម្ដេច ? ឲ្យបានរូបកាយធាត់ធំមាំមួន ? ត្រូវហាត់ប្រាណនៅទីណា ? ក្នុងពេលហាត់ប្រាណមិនត្រូវធ្វើរាយមាយឲ្យសោះ ៗ ត្រូវចំប្រឹងប្រែងឲ្យមាំមួន ទើបបានរូបកាយនោះសមល្អ ហើយជម្ងឺរោគាក៏មិនអាចនឹងបៀតបៀនបានផង ៗ ម្យ៉ាងទៀតត្រូវហាត់ដើរក្នុង១ ថ្ងៃឲ្យបាន ២ ម៉ោងដេកពីព្រលប់ ក្រោកពីព្រលឹម ឲ្យខ្យល់អាកាសចូលក្នុងដំណេកឲ្យបរិបូណ៌ ៗ

មេរៀនសង្ខេប សុំគ្រូតែងផងចុះ ៗ

## អាទិត្យទី ២ ការសំអាតខ្លួនប្រាណ

កាលណាឯងរត់លេងហាលក្ដៅ ឯងឃើញមានអ្វីនៅលើស្បែកឯង ? ឲ្យសិស្សយកដៃជូតមុខវាយកមកមើល តើវាមើលឃើញមានអ្វីៈ ញើសស្អិតដូចប្រេង ៗ ឲ្យវាលិតមើលតើទឹងដឹងដូចម្ដេច ? ប្រៃ ៗ ហិតក្លិនមើល ៗ ធុំអាក្រក់ ៗ

កាលណាធូលីហុយមកប៉ះនឹងបង្កើតទៅជាអ្វី? ក្អែល ៗ ក្អែលបណ្តាលឲ្យបានយ៉ាងណា? បុករន្ធញើសមិនឲ្យចេញ ៗ មនុស្សណាដែលញើសមិនចេញស្រួលត្រូវធ្វើដូចម្តេច ៗ

មេរៀនសង្ខេប - មនុស្សត្រូវថែរក្សាស្បែកឲ្យស្អាត ពីព្រោះស្បែកនេះហើយដែលជាប្រដាប់សម្រាប់បញ្ចេញញើសដែលជាវត្ថុសៅហ្មងដល់រូបកាយយើងហេតុនេះត្រូវដុះលាងនឹងសាប៊ូជារឿយ ៗ ត្រូវលាងដៃឲ្យស្អាត ៗ ក្រចកដៃក្រចកជើងត្រូវកាត់ឲ្យខ្លី ៗ

## វិធីបង្ការរោគ

### អាទិត្យទី ១ អំពីភ្នែក និងការថែរក្សាភ្នែក

សុំមើលមេរៀនក្នុងសៀវភៅវិធីបង្ការរោគទំព័រលេខ ១៨ ៗ

### អាទិត្យទី ២ អំពីត្រចៀក និងកាថែរក្សាត្រចៀក

សុំមើលក្នុងសៀវភៅដដែលទំព័រទី ២២

### អាទិត្យទី ៣ អំពីធ្មេញ និងការថែរក្សាធ្មេញ

មើលសៀវភៅដដែលទំព័រ ១៥

## អាទិត្យទី ៤    អំពីការថែរក្សាសក់

សុំមើលសៀវភៅដដែលទំព័រ ២៣

---

### កុមារដ្ឋាន

### វិត្ស្វាធ្យាយន៍

## អាទិត្យទី ១    អំពីស្ដាំឆ្វេង

ការបង្រៀនក្នុងខែកញ្ញានេះ សិស្សនៅថ្នាក់កុមារដ្ឋានពុំទាន់ចេះមើលចេះសរសេរនៅឡើយ សុំគ្រូហ្វឹកហ្វឺនឲ្យចាំស្ទាត់តែខាងវិធីហាត់ ហើយនឹងប្រាប់ពន្យល់ឲ្យចាំប្រាកដផង ។

### មេរៀនលេខ ១ អំពីស្ដាំឆ្វេង

នាំសិស្សឲ្យពិនិត្យមើលឲ្យដឹងស្ដាំឆ្វេង ។

ឯងមានដៃប៉ុន្មាន ? ដៃទាំង ២ នេះមានឈ្មោះឬទេ ? ដៃនេះឈ្មោះដូចម្ដេច ? ដៃនេះទៀតឈ្មោះអ្វី ? ដៃទាំង ២ ដៃណាធ្វើការច្រើនជាងគេ ? ឲ្យសិស្សលើកដៃទាំងអស់គ្នាតាមគ្រូចោទ ។

នៅខាងស្តាំឯងមានអ្វី? បើឯងបែរមុខទៅខាងជើងទិសណានៅខាងស្តាំឯង? ទិសណានៅខាងឆ្វេងឯង? ទិសណានៅខាងមុខឯង? ទិសណានៅខាងក្រោយឯង? បើឯងដើរតាមផ្លូវត្រូវដើរខាងណា? ចុះបើបររទេះក្តី ជិះសេះក្តីត្រូវកាន់ខាងណា?

ពីព្រោះអ្វីបានជាគេឲ្យប្រកាន់ខាងស្តាំយ៉ាងនេះ?

កុំឲ្យជល់ទង្គិចគ្នាក្នុងវេលាដែលជួបគ្នា ចុះបើឯងជិះទូកឬកប៉ាល់ចុះបណ្តោយតាមទឹក ខាងណាដែលហៅថាត្រើយស្តាំ? ត្រើយណាដែលហៅត្រើយឆ្វេង ។ល។

## មេរៀនចាំមាត់ សេចក្តីសង្ខេប

ត្រូវឲ្យស្គាល់ស្តាំឆ្វេង ដៃស្តាំធ្វើការច្រើនជាងដៃឆ្វេង ទៅណាមកណាត្រូវកាន់ខាងស្តាំជាដរាប ដើម្បីជៀសវាងកុំឲ្យទង្គិចគ្នា នៅវេលាដែលជួបគ្នា ។

## អាទិត្យទី ២ អំពីច្បាប់ដើរនៅផ្លូវ

សុំគ្រូរំលឹក សិស្សពីមេរៀនមុន ហើយនាំសិស្សមកច្បាប់របៀបដើរហើយនិងផ្លូវកាត់ផ្លូវនៅមុខថ្នាក់ ។

១ – វេលាណាដែលយើងនៅផ្លូវ យើងត្រូវចេះច្បាប់ដើរពីព្រោះផ្លូវតែងមាន គ្រោះថ្នាក់ជានិច្ច លើរូបអ្នកដែលមិនប្រយ័ត្ន ៗ នៅទីក្រុងនៅផ្លូវនិមួយ ៗ មានរទេះតិចឬច្រើន? យើងត្រូវដើរដូចម្តេចតាមផ្លូវ? វេលាឆ្លងកាត់ផ្លូវត្រូវធ្វើដូចម្តេច? វេលាឆ្លងផ្លូវមានរទេះបរមកចំខ្លួនត្រូវជៀសដូចម្តេច? ទៅខាងណា? មិនត្រូវតក់ឆ្លេឆ្លាដោយភ័យត្រូវគិតមើលឲ្យស្រួលបើគួរឈប់ត្រូវឈប់ឲ្យរទេះជៀសវិញ បើចង់គេចត្រូវគេចទៅតែខាងស្តាំជានិច្ច ៗ

២ សេចក្តីចោទសួរ បើជិះទោចក្រយាន ត្រូវប្រកាន់ខាងណា? បើចង់បត់ឆ្វេងស្តាំត្រូវធ្វើដូចម្តេច ៗ ល ៗ

៣ សេចក្តីសង្ខេប ទោះដើរនៅថ្នល់ក្តី ជិះកង់ក្តី ឬជៀសរទេះឡានក្តី ក៏គប្បីប្រកាន់ស្តាំជានិច្ច ដើម្បីជៀសវាងគ្រោះថ្នាក់ ៗ

## វត្តស្វាធ្យាយន៍

### អំពីថ្ងៃ

អាទិត្យទី ១ សុំគ្រូរកប្រក្រតិទិនបារាំង-ខ្មែរមកឲ្យសិស្សមើលថ្ងៃខែឆ្នាំ ៗ កំណត់ពេលវេលាក្នុងមួយថ្ងៃ ពីអធ្រាត្រទៅដល់ទីងថ្ងៃ

ត្រង់ហៅថាព្រឹក ពីថ្ងៃត្រង់ទៅទល់នឹងអធ្រាត្រហៅថាល្ងាច ពេលទាំងពីរនេះមួយ ៗ មាន ១២ ម៉ោង មួយម៉ោងមាន ៦០ នាទី មួយមីនុតមាន ៦០ វិនាទី ។

ក្នុងមួយអាទិត្យមានប្រាំពីរថ្ងៃ ឲ្យសិស្សរាប់ថ្ងៃទាំង ៧ នោះ ។

ក្នុងមួយខែមាន ២៩ ថ្ងៃ ឬ ៣០ ថ្ងៃ ១២ ខែត្រូវជាមួយឆ្នាំ ។

## អាទិត្យទី ២ អំពីខែ

សុំគ្រូរកមហាសង្ក្រាន្តខ្មែរមកបង្ហាញឲ្យចេះមើលផង ខែខ្មែរបែកជាពីរចំណែក គឺខ្នើតមាន ១៥ ថ្ងៃ រនោចមាន ១៤ ថ្ងៃ ឬ ១៥ ថ្ងៃ ។

ថ្ងៃ ១៥ កើតគេហៅថាថ្ងៃពេញបូណ៌មី ពីព្រោះយប់ថ្ងៃនោះព្រះចន្ទ្រពេញវង់ ថ្ងៃ ១៤ រោច ឬ ១៥ រោចគឺថ្ងៃខែដាច់ ។

ដូច្នេះក្នុងមួយខែខ្មែរមាន ២៩ ថ្ងៃ ឬ ៣០ ថ្ងៃជាកំណត់ដរាប ក្នុង ១ ឆ្នាំមាន ១២ ខែ ។

( ឲ្យសិស្សមើលលើមហាសង្ក្រាន្តខ្មែរ ។

គឺខែ មិគ្គសិរ . បុស្ស - មាឃ - ផល្គុន - ចេត្រ - ពិសាខ - ជេស្ឋ - អាសាឍ - ស្រាពណ៍ - កទ្របទ - អស្សុជ នឹង កត្តិក ឲ្យរៀនសំគាល់លេខខែផង ជាការមានប្រយោជន៍ក្នុងសំបុត្រស្នាមដូចជាគេសរសេរថាថ្ងៃ ២ ៥ ។ ១០ គឺថាថ្ងៃច័ន្ទ ៥ កើតខែកទ្របទ ។

មេរៀនសង្ខេបសូមឲ្យគ្រូតែងផងចុះ ។

## អាទិត្យទី ៣ អំពីរៀនមើលប្រក្រតិទិន

យកប្រក្រតិទិនមកបង្ហាញឲ្យសិស្សមើលថ្ងៃខែ ។

## អាទិត្យទី ៤ អំពីរដូវនៅស្រុកខ្មែរ

នៅនគរខ្មែរយើងតាមធម្មតា មានរដូវពីរគឺ រដូវប្រាំង នឹង រដូវវស្សា រដូវប្រាំងចាប់តាំងពីពាក់កណ្ដាលខែកត្តិក ទៅទល់នឹងពាក់កណ្ដាលខែជេស្ឋ រដូវវស្សា ពីពាក់កណ្ដាលខែជេស្ឋទៅទល់ដើមខែកត្តិក ។

រដូវប្រាំងគ្មានភ្លៀងធ្លាក់ទេ គឺជារដូវមានប្រយោជន៍ខាងអ្នកធ្វើចំការ រដូវវស្សាត្រូវខាងអ្នកធ្វើស្រែ ។

សុំគ្រូពន្យល់នឹងតែងសេចក្ដីសង្ខេបផងចុះ ។

## វិធីបង្ករភោគ

### អាទិត្យទី១— អំពីការសំអាតខ្លួនប្រាណ

ក្នុងខែនេះ ដោយសិស្សពុំទាន់ចេះមើលចេះសរសេរនៅឡើយ គ្រូគោងបង្ហាញតែខាងវិធីហាត់ឲ្យមែនទែន ហើយនឹងចោទមាត់ទទេឲ្យ

ចាំប្រាកដក្នុងការសំអាតខ្លួន ។

១ - គ្រូចាត់សិស្សម្នាក់ដែលមិនស្អាតឲ្យទៅឈរនៅមុខសិស្សឯទៀត រួចហើយនាំសិស្សឯទៀតឲ្យពិនិត្យខ្លួនប្រាណ ដៃជើងមុខមាត់ឲ្យគ្រប់កន្លែង ។ល។

សិស្សដែលឈរនេះឈ្មោះអ្វី? នៅត្រង់ណាទៀតដែលមានក្អែលច្រើន? ឯងធុំក្លិនអ្វីកាលឯងមកឈរជិតវា? ក្អែលនៅលើស្បែកបិទរន្ធអ្វី? ក្មេងស្មោកគ្រោកដូចជានេះបានសេចក្តីសុខសប្បាយឬទេ? នាំបង្កើតរោគអ្វី? ។ល។ ត្រូវធ្វើដូចម្តេចទើបស្អាត? ឯងត្រូវងូតទឹកដូចម្តេច? កាលណាងូតទឹកត្រូវដុសសាប៊ូខ្លួនប្រាណដូចម្តេច? ត្រូវប្រើអ្វីទើបជ្រះក្អែលល្អ ។ បើគ្មានសាប៊ូឯងត្រូវយកអ្វីប្រើជំនួស? យ៉ាងហោចក្នុង១អាទិត្យត្រូវដុសខ្លួនប្រាណប៉ុន្មានដង ។

ការសំអាតខ្លួនប្រាណមានប្រយោជន៍ដូចម្តេចខ្លះ ។ល។

២– សេចក្តីសង្ខេប ប្រយោជន៍សុខសាន្ត ត្រូវសំអាតប្រាណ ឲ្យបានហ្មត់ហ្មង ដុសសព្វដៃជើង គ្រប់សារពាង្គផង ទើបរួចកន្ទង់ ពីការស្មោកគ្រោក ។ ចូរចាំកុំភ្លេច មនុស្សណាគគ្រេច មិនដែលអ្នកផង ចូលចិត្តចង់ជិតស្នេហ៍ស្និទ្ធសាសង នឹងមនុស្សនេះហោង ដោយខ្ពើមរអើម ។

## អាទិត្យទី២- របៀបប្រើសាប៊ូ

កាលណាគេបោកលាងសម្លៀកបំពាក់តែនឹងទឹកទទេ គេបានស្អាតឬទេ បើដូច្នេះខ្លួនប្រាណយើងក៏ត្រូវដុសលាងនឹងទឹកហើយនឹងសាប៊ូដែរ កាលណាឯងងូតទឹកសាប៊ូនាំឱ្យបាត់ក្អែលបំបាត់ក្លិនអាក្រក់ ដែលដុសសំលៀកបំពាក់នឹងសាប៊ូល្អ គេដុសខ្លួនប្រាណនឹងសាប៊ូក្រអូបវេលាដែលដុសសាប៊ូត្រូវដុសឱ្យយូរសឹមលាងទឹកចេញ ។

### អំពីទឹកឆ្អិន

ធ្វើដូចម្ដេចឱ្យបានទឹកឆ្អិនសុទ្ធផឹកតាមត្រូវការ? យើងយកថ្នាំប៉េរ-ម៉ង់តាណាត មកលាយនឹងទឹកក៏បានដែរ ប៉ុន្តែអ្នកស្រុកពុំធាប់ប្រើតាមធម្មតា គេយកទឹកមកដាំឱ្យពុះចំនួន ១៩ មីនុត ទើបយកមកផឹក ការទំលាប់ផឹកទឹកក្ដៅនេះ នាំឱ្យយើងជៀសវាងជម្ងឺច្រើនប្រការ កាលណាស្រុកមានជម្ងឺ ៗ យើងចង់ឱ្យទឹកនោះមានក្លិនរសជាតិល្អ ត្រូវធ្វើដូចម្ដេចទៀត? យួនចិនប្រើទឹកតែ ជាប់ជាធម្មតា ៗ ខ្មែរយើងក៏ប្រើដែរ ខ្លះប្រើទឹកឫសដង្ហិតស្មៅឫសដូងព្រះ ៗ ទំលាប់យ៉ាងនេះជាការសំខាន់ព្រោះគេសង្ឃះនេះមានគុណប្រយោជន៍ហើយថ្លៃតិចផង ។

# វិធីបង្ការរោគ

ឯរបៀបបង្រៀនវិធីបង្ការរោគ ដែលមានពាយខាងក្រោមនេះ សុំគ្រូយកក្មេងណាមួយមកដុសលាងខ្លួនវានៅមុខសិស្សទាំងអស់ ដើម្បីឲ្យវារៀនធ្វើតាមខ្លួនឯងមិនចាំបាច់ម្ដាយឪពុកធ្វើឲ្យ ឯការពន្យល់តែមាត់ទទេមិនគ្រប់គ្រាន់ទេ ។

អាទិត្យទី១- ការសំអាតខ្លួនប្រាណ ។

អាទិត្យទី២- ការលុបលាងមុខទឹងក្អែកហើយទឹងត្រចៀក ។

អាទិត្យទី៣- ការសំអាតក្រចកដៃជើង ។

អាទិត្យទី៤- ការសំអាតធ្មេញ ។

សុំគ្រូយកច្រាសទឹងថ្នាំដុសធ្មេញមកឲ្យក្មេងវាដុស ដើម្បីវាចេះប្រើចេះសំអាតធ្មេញវា ។

# លោកនីតិ

## សំរាប់គ្រូបង្ហាត់

អាទិត្យដំបូង.- ប្រទេសកម្ពុជា

កម្ពុជាគឺជាផែនដីមួយកន្លែងក្នុងសកលលោក ជាប្រទេសរបស់ខ្មែរ មានព្រះមហាក្សត្រិយ៍សោយរាជ្យ ។ របៀបរាជការក៏មានគ្រប់គ្រាន់ដូចប្រទេសដទៃដែរ គឺមានរដ្ឋសភា ក្រុមព្រះរាជអាណាចក្រ រដ្ឋាភិបាល និងតុលាការ ។ រដ្ឋសភាគឺទីប្រជុំអ្នកតំណាងរាស្ត្រ សម្រាប់ប្រឹក្សាច្បាប់ទំនុកបំរុងគ្រប់គ្រងរដ្ឋ ។ ក្រុមព្រះរាជអាណាចក្រត្រូវពិនិត្យនិងឲ្យយោបល់អំពីសេចក្តីព្រាងច្បាប់និងស្នើច្បាប់ដែលរដ្ឋសភាបានបញ្ចេញមតិយល់ព្រមរួចហើយ រដ្ឋាភិបាលគឺគណៈរដ្ឋមន្ត្រីនៃព្រះមហាក្សត្រិយ៍គឺមន្ត្រីទំនុកបំរុងប្រទេសមានចំនួនយ៉ាងច្រើនត្រឹមដប់ពីររូប រាប់បញ្ចូលទាំងរដ្ឋលេខាធិការផង តុលាការគឺក្រសួងជំរះក្តីស្ងួនជីងការមិនឲ្យលំអៀង ។

ពាក្យសួរ ៈ — ប្រទេសកម្ពុជា ជាប្រទេសរបស់ជាតិណា ? ព្រះមហាក្សត្រិយ៍ព្រះនាមអ្វី ? របៀបរាជការអ្វីខ្លះដែលអ្នកស្គាល់ ? រដ្ឋសភាសម្រាប់ធ្វើអ្វី ? ។ល។

មេរៀនសង្ខេប ៈ — ប្រទេសកម្ពុជា ជាប្រជាជាតិមួយក្នុងសកលលោកមានមហាក្សត្រិយ៍សោយរាជ្យ ។ ឯរបៀបរាជការក៏មានគ្រប់គ្រាន់ពេញលេញដូចប្រទេសដទៃដែរ មានរដ្ឋសភាក្រុមព្រះរាជអាណាចក្ររដ្ឋាភិបាលនិងតុលាការ ។

អាទិត្យក្រោយ ៈ — អំពីភូមិនិងឃុំ

តំបន់ណាដែលមានប្រជុំផ្ទះលំនៅច្រើនហៅថាភូមិ ។

ភូមិរួមគ្នាពីរឬបីឡើងទៅបានជាឃុំមួយ មានមន្ត្រីម្នាក់ជានាយកត្រួតត្រាហៅថាមេឃុំ ។ នៅក្រុងភ្នំពេញគេចែកឃុំជាសង្កាត់ ៗ ។ អ្នកត្រួតត្រាសង្កាត់និមួយៗហៅថាមេសង្កាត់ ។

មេឃុំមានស្មៀននិងជំទប់ជួយធ្វើការ ទារពន្ធដារពីរាស្ត្រតាមច្បាប់បញ្ញត្តិមេឃុំ ជាអាណាព្យាបាលលើឃុំជួយទំនុកបំរុងរាស្ត្រឱ្យបានសន្តិសុខ ។

ពាក្យសួរ.— អ្នកនៅភូមិណា ពីព្រោះអ្វីបានគេហៅឈ្មោះភូមិអ្នកយ៉ាងដូច្នេះ? ភូមិអ្នកតូចឬធំ? មានមនុស្សនៅប្រហែលប៉ុន្មាននាក់ពីព្រោះអ្វីបានជាគេកសាងភូមិអ្នកនៅទីនោះ ? អ្នកណាត្រួតត្រាលើភូមិអ្នក? យ៉ាងដូចម្តេចដែលហៅថាឃុំ? មេឃុំធ្វើអ្វីខ្លះ ។ល។

មេរៀនសង្ខេប.— ភូមិគឺតំបន់ដែលមានប្រជុំផ្ទះលំនៅច្រើន ភូមិណាធំទូលាយមានផ្លូវកាន់គ្នាទៅវិញទៅមកបានដោយងាយភូមិនោះមានមនុស្សនៅច្រើនជាងគេ ។

ឃុំគឺទីប្រជុំភូមិច្រើនឬតិចតាមបញ្ញត្តិរាជការរដ្ឋបាល នៅក្នុងអំណាចមេឃុំម្នាក់ៗ ។ មេឃុំជាអាណាព្យាបាការពាររាស្ត្រឱ្យបានសន្តិសុខមានស្មៀននិងជំទប់ជួយធ្វើការ ទារពន្ធដារពីរាស្ត្រតាមច្បាប់បញ្ញត្តិ ។

មេឃុំ.— នៅក្នុងឃុំនិមួយ ៗ មានមន្ត្រីម្នាក់ជាអាណាព្យាបាលលើឃុំដែលរាជការរដ្ឋបាលឲ្យងារជាមេឃុំ ។

មេឃុំមានស្មៀនម្នាក់មានជំទប់ក្រុមជំនុំនិងមេភូមិជួយធ្វើការជំទប់ ៤ នាក់តាមធម្មតា ។

មេឃុំត្រូវការពារពន្ធគ្រប់ជំពូកក្នុងឃុំ ត្រូវទទួលពាក្យបណ្ដឹងពីរាស្ត្រ ហើយផ្សះផ្សាទៀតផង បើគូសត្រូវពុំសុខចិត្តត្រូវបញ្ជូនពាក្យនោះទៅចៅហ្វាយស្រុកតាមរយៈ ដើម្បីឲ្យតុលាការជំនុំជំរះតាមច្បាប់ ។

ពាក្យសួរ.— ភូមិអ្នកនៅក្នុងឃុំណា ? អ្នកណាត្រួតត្រាលើឃុំ ? មុខក្រសួងមេឃុំយ៉ាងណាខ្លះ ? ។ល។ ។

## មនុស្សបំណុះឃុំ

គ្រប់ភូមិគ្រប់ឃុំនៃប្រទេសកម្ពុជាយើង ពុំមែនមានសុទ្ធតែជាតិខ្មែរទេ គឺមានបរទេសដែរ ដូចចិនយួនជាដើម មានរបរកស៊ីផ្សេងពីគ្នា ប៉ុន្តែជនទាំងនេះទុកជារាស្ត្របំណុះឃុំដូចគ្នា ពីព្រោះមានទីលំនៅក្នុងរយៈឃុំនោះហើយបានបង់ពន្ធគ្រប់ជំពូកជូនរាជការក្នុងឃុំនោះផង ។ បណ្ដាជនក្នុងឃុំត្រូវឲ្យដឹងករណីយកិច្ចរបស់ខ្លួន ។

ត្រូវជួយទំនុកបំរុងរាជការឃុំ វេលាដែលមានអាសន្នប្រតិបត្តិតាម

ច្បាប់បញ្ញត្តិដូចមានខាងក្រោមនេះ ៖

ត្រូវបង់ពន្ធគ្រប់ជំពូកជូនមេឃុំតាមច្បាប់បញ្ញត្តិ

ត្រូវប្តឹងភ្នាក់ងារឃុំ កាលណាមានមនុស្សទុច្ចរិតឬមនុស្សអាក្រក់ផ្សេងៗ ។

បើចង់ទៅនៅទីកន្លែងណាទៀតត្រូវប្តឹងមេឃុំឲ្យបំណាយឈ្មោះចេញពីបញ្ជីឃុំចាស់ ។

ត្រូវយកកូនទៅសុំបណ្តុះអុតទឹងចាក់ថ្នាំការពារជម្ងឺផ្សេងៗ បើកូនអាយុបាន ៦ ឆ្នាំហើយត្រូវបញ្ជូនទៅសាលារៀនកុំខាន ។

បើរើសបានវត្ថុអ្វីក្តី ចាប់បានសត្វពាហនៈក្តី ដែលពុំមានម្ចាស់ ត្រូវដឹកនាំយកទៅឲ្យភ្នាក់ងារឃុំយ៉ាងឆាប់ បើមានកូនកើត ឬស្លាប់ ឬធ្វើបុណ្យផ្សេងៗ ត្រូវប្តឹងមេឃុំ ។

ពាក្យសួរ.- យ៉ាងដូចម្តេចដែលហៅថាមនុស្សចំណុះឃុំ ? ករណីយកិច្ចបណ្តាជនក្នុងឃុំត្រូវធ្វើដូចម្តេចខ្លះ ។ល។

អំពីស្រុក.- ឃុំច្រើនរួមបានជាស្រុក ។ ក្នុងស្រុកនិមួយៗ មានមន្ត្រីម្នាក់ងារជាចៅហ្វាយស្រុក ជាអ្នកត្រួតត្រាមើលការខុសត្រូវលើស្រុក ។

ចៅហ្វាយស្រុកមានបាឡាត់ស្រុក យោក្ប័ត្រ ស្មៀន និងប៉ូលិសជួយធ្វើការ ។ ក្រសួងៈ ហ្វាយស្រុកដូចមានខាងក្រោមនេះ ។

១– ត្រូវធ្វើឲ្យរាស្ត្របានសេចក្ដីសុខ បំបាត់ចោរកំណាចចេញពីក្នុងស្រុកដើម្បីឲ្យបានចំរើនខាងភោគសម្បត្តិហើយឲ្យដឹងសេចក្ដីក្រខ្វត់អត់ឃ្លាននៃបណ្ដារាស្ត្រទៀតផង ។

២ ត្រូវរៀបចំស្រុកឲ្យបានថ្កើងរុងរឿង ធ្វើផ្លូវធ្វើស្ពានជីកព្រែកឲ្យចំរើនធនធានទីផ្លូវកាន់គ្នាទៅវិញទៅមកដល់ស្រុក ។

៣ - ត្រូវប្រឹងប្រែងខំប្រមូលប្រាក់ពន្ធ ពីមេឃុំ នានា យកទៅដាក់ឃ្លាំងឲ្យបានទាន់ពេលវេលា ។

៤ - ត្រូវខ្នាន ពន្យល់ បណ្ដារាស្ត្រ ក្នុងស្រុកឲ្យប្រព្រឹត្ត ត្រឹមត្រូវ ពន្យល់អំពីរបៀបរកស៊ីអំពីវិទ្យាសាស្ត្រដើម្បីបំបាត់សេចក្ដីល្ងង់ខ្លៅចោលចេញ ។

ពាក្យសួរ.– ឃុំអ្នកនៅក្នុងស្រុកណា ? យ៉ាងដូចម្ដេចដែលហៅថាស្រុក ? នៅក្នុងស្រុកនិមួយ ៗ មានមន្ត្រីណាខ្លះ ? ចៅហ្វាយស្រុកធ្វើអ្វីខ្លះ ?

អំពីខេត្ត.– ស្រុកច្រើនរួមកើតបានជាខេត្ត មានមន្ត្រីម្នាក់ជាន់ខ្ពស់ងារជាចៅហ្វាយខេត្តត្រួតត្រាមើលការខុសត្រូវលើចៅហ្វាយស្រុកទាំង

មន្ត្រីឯទៀតនៅក្នុងខេត្ត ។ នៅប្រទេសកម្ពុជាមាន ១៤ ខេត្តគឺ: ខេត្តកណ្ដាល - កំពង់ស្ពឺ - តាកែវ - កំពត - ព្រៃវែង - ស្វាយរៀង - កំពង់ចាម - ក្រចេះ - ស្ទឹងត្រែង - កំពង់ធំ - កំពង់ឆ្នាំ - ពោធិ៍សាត់ - សៀមរាប - បាត់ដំបង ។

ក្រសួងចៅហ្វាយខេត្តដូចមាន ខាងក្រោមនេះ

១– ត្រូវប្រមូលប្រាក់ពន្ធគ្រប់មុខពីចៅហ្វាយស្រុក ។

២– ត្រូវរៀបចំខេត្តឲ្យបានចំរើនរុងរឿងឲ្យបាន សន្តិសុខ និងចំរើន នូវភោគសម្បត្តិ ។

៣– ត្រូវទទួលពត៌មានផ្សេងៗ ពីចៅហ្វាយស្រុក ហើយពិនិត្យមើលឲ្យបានត្រឹមត្រូវរួចបញ្ជូនទៅតាមក្រសួង ។

៤– ត្រូវទទួលបង្គាប់បញ្ញត្តិនានាអំពីរដ្ឋមន្ត្រី ហើយចាត់ការបង្គាប់ទៅចៅហ្វាយស្រុកឲ្យប្រតិបត្តិតាម ។

# មេសូត្រត់មាត់

## (សំរាប់គ្រប់ថ្នាក់)

---

## ១– ការប្រព្រឹត្តនៃត្រកូលខ្មែរ

នៃអស់កុមារ  មាតាបិតា  ជាអ្នកមានគុណ
បីបាច់ថែអ្នក  លំបាកយ៉ាងធ្ងន់  ទ្រាំទ្រអត់ធន់
ពីតូចដល់ធំ ៗ  លុះអ្នកធំក្តី  លោកមានហឫទ័យ
បង់ឲ្យស្តុកស្តម្ភ  ធ្វើការសព្វយ៉ាង  ប្រឹងប្រែងស៊ូទ្រាំ
ខ្វះអ្វីទិញផ្សំ  ឲ្យអ្នកសិក្សា ៗ  ចេះត្រូវអ្នកដឹង
រិះរំពឹង  គុណលោកម៉្លេះណា  បងត្រូវថែប្អូន
ដោយចិត្តស្នេហា  ជំនួសមាតា  បិតាអ្នកផង ៗ

ពាក្យពន្យល់– ស្តុកស្តម្ភ=(ម. ថ. ស្តុក-ស្តំ) មាំមួន ៗ

---

## ២– ការគោរពមាតាបិតា

កុមារឧត្តម  ទាំងតូចទាំងធំ  ត្រូវតែគោរព
មាតាបិតា  ឧបមាដូចម្លប់  ជាទីជ្រកឈប់

នៃបុត្រធីតា ៗ ប្រុះត្រូវកោតខ្លាច លុះដោយអំណាច
លោកជាមេបា កាលអ្នកនៅក្មេង លោកថែរក្សា
អ្នកធំកាលណា រក្សាលោកវិញ ៗ លោកបង់ពិសា
ចំណីអាហារ ដែលមានរស់ឆ្ងាញ់ អ្នកត្រូវស្វែងរក
យកប្រាក់ទៅទិញ ដើម្បីបំពេញ បំណាច់នៃលោក ៗ
បើលោកប្រើប្រៀន ខាងផ្លូវសូត្ររៀន ឬស្វែងទ្រព្យគោត
អ្នកត្រូវប្រឹងស្តាប់ ដោយគោរពលោក ត្រូវអ្នកកុំក្រោក
ពេលលោកនិយាយ ៗ

ពាក្យពន្យល់ .–

ឧត្តម = ( ម. ថ អ៊ុត-ដំ ) ខ្ពង់ខ្ពស់ ៗ
ធីតា = ( ម. ថ ធី-ដា ) កូនស្រី ៗ
មេបា = ( ម្តាយឪពុក ៗ

---

## ៣– សេចក្តីស្នេហាចំពោះបងប្អូន

បងប្អូនប្រុសស្រី ទោះតូចធំក្តី គោរពស្រឡាញ់គ្នា
រាប់អានស្នេហ៍ស្និទ្ធ ផ្ញើចិត្តមេត្តា កុំទាស់ទែងគ្នា

ជាការមិនល្អ ៗ បងត្រូវថ្នមប្អូន ឲ្យដូចជាកូន

ចេញពីទ្វារ ប្អូនត្រូវគោរពខ្លាច កុំអាចតបត

ទើបអ្នកបានល្អ ឋាវរពេកក្រៃ ៗ ចរចារគ្នា

ប្រើពាក្យសោភា បន្ទន់សំដី ពោលចំពោះប្អូន

ចំពោះបងក្តី គោងតែគិតតែ លៃលកឲ្យសម ៗ

ទើបអ្នករក្សា សុខឥតទុក្ខា មកលាយប្រឡំ

ព្រោះតែអ្នកប្រើ សំដីគួរសម ឥតឆ្គងឥតឆ្គាំ

រម្យរម្យបិតថេរ ៗ

ពាក្យពន្យល់ . –

ទ្វារ = ពោះ ផ្ទៃ ៗ ឋាវរ =( ម. ថ. ប. រ៉ )

ប្រសើរ ៗ សោភា = សម, ល្អ

---

## ៤– សេចក្តីស្នេហាចំពោះបងប្អូន (ត)

កិច្ចការពក់ជ្រៅ បងត្រូវប្រដៅ ដោយចិត្តស្និទ្ធស្នេហ៍

ប្អូនមានកំហុស គិតខុសវៀចវេរ ទំនាស់អ្នកគេ

ប្រាប់កុំបន្ទន់ ៗ មហ៊ឺនទៀតដេផ្លា ត្រូវកាន់កិរិយា
រក្សាផៅពង្ស ធ្វើខ្លួនឲ្យល្អ ស្មោះសរស្លូតត្រង់
ការគោរពពូជវង្ស ឬជាតម្រាប់ ៗ ប្អូនធ្វើតាមក្រោយ
ពុំហ៊ានបណ្តោយ តែងតែធ្វើត្រាប់ ប្រព្រឹត្តកោតក្រែង
យកបងជាច្បាប់ ធ្វើច្នេះទាល់ស្លាប់ ពុំបែកគ្នាឡើយ

ពាក្យពន្យល់ – ដេផ្លា = បង ៗ ស្មោះសរ = សេចក្តីរីករាយរាក់ទាក់ ៗ តម្រា = ក្បួន, ច្បាប់ ៗ

---

## ៥– ត្រូវសំអាតខ្លួនជានិច្ច

ចូរអ្នកសំអាត ខ្លួនឲ្យបានស្អាត បំបាត់ខ្មោះជូរ
ឧស្សាហ៍ងូតទឹក ដុសដោយសាប៊ូ តាមឱវាទគ្រូ
ឲ្យសុខដល់អ្នក ៗ ប្រដាប់ប្រដា ដែលអ្នកត្រូវការ
នឹងស្លៀកឬពាក់ កុំឲ្យក្រខ្វក់ ពក្វក់ប្រឡាក់
អាហារក៏អ្នក ត្រូវតែសំអាត ៗ មុនពេលបរិភោគ
ត្រូវកុំស្មោកគ្រោក លាងដៃឲ្យស្អាត បើមានប្រឡាក់
តោងអ្នកសង្វាត ជំរះសំអាត ឲ្យស្អាតជាប ៗ

ម្យ៉ាងទៀតភ្នែកអ្នក  បើដៃប្រឡាក់  អ្នកកុំពាល់ស្ទាប

អាចបណ្ដាលរោគ  ឲ្យអន្ធភាព  ផុតបេះបូរជ្រាប

ទោសនៃស្មោកគ្រោក ៗ

ពាក្យពន្យល់.– ពក្ល់–ដែលមានសម្បុរគាប់គន់, សៅហ្មង

អន្ធភាព – ( អ. ថ. អន់-ធៈ-ភាព )

ភាពខ្វាក់, ងងិតភ្នែក ៗ

---

## ៦– ចូរខំធ្វើការ

យើងខំធ្វើការគ្រប់គ្នា  ទោះជាពិបាកដូចម្ដេចក្ដី

ព្រោះមនុស្សរាល់រូបក្នុងលោកិយ  បានរស់មកពីខំធ្វើការ ៗ

មនុស្សឲ្យមានទីលំនៅ  យើងត្រូវបរិភោគអស់អាហារ

សំពត់អាវបិទបាំងអាត្មា  មិនដែលអ្នកណាបានទទេ ៗ

ត្រូវធ្វើឬទិញទើបបានមក  លុះតែយើងរកប្រាក់ទិញគេ

បើចង់បានប្រាក់ត្រូវរិះរេ  កុំនៅទំនេរខំធ្វើការ ៗ

ការនេះមានគុណប្រសើរណាស់  នាំកុំខ្ជិលផ្ដាសត្រូវឧស្សាហ៍

ការនេះនាំឲ្យមានប្រាជ្ញា  ឲ្យមានកិរិយាល្អប្រពៃ ៗ

មួយទៀតចំណែកខាងធនធាន នឹងមានសម្បត្តិគប់ច្រើនក្តី

ហេតុនេះចូរកុមារប្រុសស្រី គប្បីត្រូវអ្នកខំធ្វើការ ៗ

ពាក្យពន្យល់.– លោកិយ លោកនេះ ៗ អាត្មា – ខ្លួន....

ឯង.....យើង ៗ ឧស្សាហ៍ – ព្រឹងប្រែង, សង្វាត

ប្រពៃ – ប្រសើរ ៗ ធនធាន - សម្បត្តិ

រោងពុម្ពខ្មែរ